ជំពូកទី ១៣

# អំពីជំងឺមួយចំនួនដែលកើតជាញឹកញាប់

## ការខ្សោះជាតិទឹក

**កុមារជាច្រើនដែលស្លាប់ដោយសារជំងឺរាក គឺស្លាប់ដោយសារពួកគេគ្មានជាតិទឹកគ្រប់គ្រាន់នៅសល់នៅក្នុងខ្លួនរបស់គេ។ ការខ្វះជាតិទឹកនេះ ត្រូវបានហៅថាការខ្សោះជាតិទឹក។**

ការខ្សោះជាតិទឹកកើតឡើងនៅពេលដែលមានការបាត់បង់ទឹកពីក្នុងខ្លួន ច្រើនជាងចំណុះទឹកដែលបានបញ្ចូល។ បញ្ហានេះកើតឡើងនៅពេលមានការរាកធ្ងន់ធ្ងរ ជាពិសេសនៅពេលដែលមានក្អួតថែមទៀត។ វាក៏អាចកើតឡើងលើអ្នកមានជំងឺធ្ងន់ ដែលមិនអាចបរិភោគអាហារ ឬមិនអាចផឹកទឹកបានគ្រប់គ្រាន់។

មនុស្សគ្រប់វ័យទាំងអស់សុទ្ធតែអាចមានការខ្សោះជាតិ **ប៉ុន្តែការខ្សោះជាតិទឹកកើតឡើងយ៉ាងលឿន និងមានគ្រោះថ្នាក់ជាទីបំផុត ចំពោះកុមារតូចៗ ។**

| **កុមារដែលមានរាកសុទ្ធតែទឹកនឹងមានគ្រោះថ្នាក់ដោយសារការខ្សោះជាតិទឹក។** |
|---|

វាជាការសំខាន់ណាស់ដែលមនុស្សគ្រប់រូប ជាពិសេសចំពោះម្តាយ បានស្គាល់អំពីរោគសញ្ញានៃការខ្សោះជាតិទឹក និងដឹងពីវិធីការពារ និងព្យាបាលវា។

*រោគសញ្ញានៃការខ្សោះជាតិទឹក ៖*

- ការស្រេកទឹក តែងតែជារោគសញ្ញាដំបូងនៃការខ្សោះជាតិទឹក
- មានទឹកនោមបន្តិចបន្តួច ឬគ្មានទឹកនោម ឬ ទឹកនោមមានពណ៌លឿងចាស់
- ការចុះទម្ងន់ភ្លាមៗ
- បបូរមាត់ស្ងួត
- ភ្នែករូងខូង និងស្ងួត
- បង្ហើយផត ចំពោះទារក
- ស្បែកបាត់បង់ភាពយឺត






ការខ្សោះជាតិទឹកធ្ងន់ធ្ងរ អាចបណ្តាលឲ្យជីពចរដើរញាប់ តែខ្សោយ(មើលស្តុកទំ.៧៧) ដកដង្ហើមញាប់ហើយជ្រៅៗ មានគ្រុនក្តៅ ឬប្រកាច់ (សម្រាប់ការប្រកាច់ សូមមើលទំ.១៧៨)។

ប្រសិនបើអ្នកជំងឺមានរាកធ្ងន់ធ្ងរ ឬមានរាកនិងក្អួតផង មិនត្រូវរង់ចាំមើលរោគសញ្ញាការខ្សោះជាតិទឹកទេ។ **ចាត់វិធានការជាបន្ទាន់** មើលទំព័របន្ទាប់។

*ដើម្បីការពារនិងព្យាបាលការខ្សោះជាតិទឹក ៖ នៅពេលមាននរណាម្នាក់មានរាកដូចទឹក ធ្វើដូចខាងក្រោមជាប្រញាប់ ៖*

- **ឲ្យអ្នកជំងឺផឹកទឹកឲ្យបានច្រើន ៖** ទឹកអូរ៉ាលីតគឺជាការប្រសើរបំផុត ឬឲ្យទឹកបបរ ទឹកតែ ទឹកស៊ុប ឬទឹកសុទ្ធ។ល។ ប៉ុន្តែមិនត្រូវរង់ចាំដល់ពេលកើតមានការខ្សោះជាតិទឹកទើបចាប់ផ្តើមឲ្យផឹកទឹកនោះទេ។
- **ត្រូវបន្តផ្តល់អាហារ ៖** នៅពេលដែលកុមារ ឬមនុស្សធំដែលមានជំងឺនោះ អាចបរិភោគបានភ្លាម ចាប់ផ្តើមផ្តល់អាហារដែលគាត់អាចបរិភោគបាន ឲ្យបានញឹកញាប់។
- ចំពោះទារក បន្ត**បំបៅដោះម្តាយ**ឲ្យបានញឹកញាប់ និងមុនពេលផឹកទឹកផ្សេងៗទៀត។

**ទឹកអូរ៉ាលីត** អាចជួយការពារ ឬព្យាបាលការខ្សោះជាតិទឹកបាន ជាពិសេសនៅក្នុងករណីរាកសុទ្ធតែទឹកយ៉ាងធ្ងន់ធ្ងរ។

<table>
<tr><th colspan="2">វិធីពីរយ៉ាងក្នុងការធ្វើទឹកអូរ៉ាលីត នៅតាមផ្ទះ</th></tr>
<tr>
<td>១. ការផ្សំជាមួយស្ករនិងអំបិល (ស្ករត្នោត ឬស្ករអំពៅ អាចប្រើជំនួសស្ករសបាន)<br><br>ក្នុងទឹកស្អាត១លីត្រ ដាក់ អំបិលកន្លះស្លាបព្រា និងស្ករ៨ស្លាបព្រា<br><br>ការប្រុងប្រយត្ន័ ៖ មុនដាក់ស្ករ ភ្លក់ទឹកមើលសិនហើយប្រាកដថាវាមានជាតិប្រៃ តិចជាងទឹកភ្នែក។<br><br>ភេសជ្ជៈណាមួយក៏បាន អាចបន្ថែមទឹកផ្លែឈើកន្លះកែវ ដូចជាទឹកដូង ឬកិនចេកទុំឲ្យហ្មត់ ប្រសិនបើអាចរកបាន។ ការបន្ថែមនេះផ្តល់ជាតិប៉ូតាស្យូម ដែលអាចជួយ ឲ្យកុមារបានទទួលអាហារនិងទឹកផង។</td>
<td>២. ការផ្សំជាមួយម្សៅធញ្ញជាតិ និងអំបិល (ម្សៅអង្ករពិតជាប្រសើរ ឬប្រើម្សៅអង្ករសាលី ម្សៅពោត ឬម្សៅដំឡូង)<br><br>ទឹកមួយលីត្រ ដាក់ អំបិលកន្លះស្លាបព្រា និងដាក់ ម្សៅធញ្ញជាតិចំនួន៨ស្លាបព្រា<br><br>ចំអិន៥ទៅ៧នាទី ឲ្យក្លាយទៅជាបបររាវៗ ទុកទឹកនោះឲ្យត្រជាក់ ឲ្យបានលឿន ហើយចាប់ផ្តើមឲ្យកុមារផឹក។<br><br>ការប្រុងប្រយត្ន័ ៖ ភ្លក់ទឹកនោះគ្រប់ពេល មុនពេលឲ្យកុមារផឹក ដោយប្រាកដថាវាមិនផ្អូម។ ទឹកផ្សំពីគ្រាប់ធញ្ញជាតិនេះអាចផ្អូមខូចក្នុងអំឡុងពេល២ឬ៣ម៉ោង នៅពេលមានអាកាសធាតុក្តៅ។</td>
</tr>
<tr><td colspan="2">សារសំខាន់ ៖ តម្រូវការធ្វើភេសជ្ជៈនេះទៅតាមតំបន់របស់អ្នក។ ប្រសិនបើនៅតាមគ្រួសារភាគច្រើន គ្មានរង្វាស់ជាលីត្រ ឬស្លាបព្រាកាហ្វេទេ ប្រើទម្រង់ផ្សេងៗនៃរង្វាស់នៅក្នុងតំបន់របស់អ្នក ដើម្បីវាស់បរិមាណនៃជាតុផ្សំទាំងនេះ។ ស្វែងរកមធ្យោបាយដែលងាយស្រួល និងសាមញ្ញ។</td></tr>
</table>

ឲ្យអ្នកខ្សោះជាតិទឹកព្យាយាមផឹកទឹកនេះបន្តិចម្តងៗរៀងរាល់ប្រាំនាទី ទាំងពេលថ្ងៃនិងពេលយប់ រហូតដល់អ្នកជំងឺចាប់ផ្តើមមានទឹកនោមដូចធម្មតា។ មនុស្សធំត្រូវការទឹកចំនួនបីលីត្រ ឬច្រើនជាងនេះ ក្នុងមួយថ្ងៃ។ ចំពោះកុមារតូចៗជាទូទៅត្រូវការទឹកយ៉ាងតិចមួយលីត្រក្នុងមួយថ្ងៃ ឬមួយកែវនៅរាល់ពេលមានការរាកម្តងៗ។ បន្តផ្តល់ទឹកម្តងបន្តិចៗឲ្យបាន**ញឹកញាប់ ទោះបីអ្នកនោះមានក្អួតក៏ដោយ**។ មិនមែនទឹកទាំងអស់ដែលបានផឹក សុទ្ធតែត្រូវបានក្អួតចេញមកវិញនោះទេ។

*បំរាម ៖* **បើការខ្សោះជាតិទឹកកាន់តែធ្ងន់ធ្ងរ ឬមានសញ្ញាគ្រោះថ្នាក់ផ្សេងទៀតកើតឡើង ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់**(មើលទំ.១៥៩)។ អ្នកជំងឺអាចត្រូវការការចាក់បញ្ចូលសេរ៉ូមតាមសរសៃឈាមជាចាំបាច់។

*កំណត់ចំណាំ ៖* នៅក្នុងប្រទេសមួយចំនួន គេអាចរកបាននូវកញ្ចប់ម្សៅអូរ៉ាលីត (ORS) សម្រាប់លាយជាមួយទឹក។ កញ្ចប់ទាំងនេះមានស្ករ អំបិល សូដា និងប៉ូតាស្យូម(ទំ.៣៨២)។ ទោះជាយ៉ាងណាក៏ដោយ ក៏ការធ្វើភេសជ្ជៈបង្គ្រប់ជាតិទឹកនេះនៅតាមផ្ទះ ជាពិសេសការធ្វើពីម្សៅធញ្ញជាតិ បើធ្វើបានត្រឹមត្រូវ ភាគច្រើនវាមានតម្លៃថោកជាង មានសុវត្ថិភាពជាង ហើយមានប្រសិទ្ធិភាពជាងម្សៅអូរ៉ាលីត(ORS) ទៅទៀត។

# ជំងឺរាគ និងរាគមួល

នៅពេលមនុស្សម្នាក់មានលាមកខាប់ៗ ឬរាវ នោះគាត់មានជំងឺរាគ ។ បើគាត់មានលាមកលាយសំបោរ និងឈាម នោះបញ្ជាក់ថាគាត់មានជំងឺរាគមួល។

ជំងឺរាគអាចមានកម្រិតស្រាល ឬកម្រិតធ្ងន់។ វាអាចមានលក្ខណៈស្រួចស្រាល់(រាគភ្លាមៗនិងធ្ងន់ធ្ងរ) ឬមានលក្ខណៈរ៉ាំរ៉ៃ (រាគជាច្រើនថ្ងៃ)។

**ជំងឺរាគ កើតមានជាញឹកញាប់ និងមានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះកុមារ ពិសេសចំពោះកុមារដែលមានការខ្វះអាហារូបត្ថម្ភ។**




ជំងឺរាគមានមូលហេតុជាច្រើនយ៉ាង។ **ធម្មតាគេមិនត្រូវការថ្នាំពេទ្យទេ** ហើយកុមារនឹងមានការធូរ ស្បើយក្នុងរយៈពេល ពីរបីថ្ងៃ បើអ្នកផ្តល់ជាតិទឹកនិងអាហារគ្រប់គ្រាន់ដល់គេ (ប្រសិនបើកុមារនោះមិនសូវបរិភោគច្រើន ឲ្យគាត់បរិភោគតិចៗ ហើយច្រើនដងក្នុងមួយថ្ងៃ)។ ជួនកាល អ្នកជំងឺនេះអាចត្រូវការការព្យាបាលពិសេស។ ប៉ុន្តែ **ជំងឺរាគភាគច្រើនអាចព្យាបាលដោយជោគជ័យនៅតាមផ្ទះ** ទោះបីជាអ្នកមិនដឹងអំពីមូលហេតុពិតប្រាកដរបស់វាក៏ដោយ។

| **មូលហេតុសំខាន់នៃជំងឺរាគ** | |
|---|---|
| កង្វះអាហារូបត្ថម្ភ (ទំ.១៥៤)។ បញ្ហានេះធ្វើឲ្យកុមារខ្សោយ ហើយធ្វើឲ្យកុមារមានជំងឺរាគ ដោយសារមូលហេតុផ្សេងៗ ជាញឹកញាប់ និងមានសភាពធ្ងន់ធ្ងរ។<br><br>ការខ្វះទឹក និងអនាម័យ(គ្មានបង្គន់) ធ្វើឲ្យមានការឆ្លងរាលដាលនៃ មេរោគដែលបណ្តាលឲ្យកើតជំងឺរាគ។<br><br>ការបង្ករោគដោយមេរោគវីរុស<br><br>ការបង្ករោគនៅពោះវៀន ដែលបណ្តាលមកពីបាក់តេរី (ទំ.១៣១) អាមីប(ទំ.១៤៤) ឬហ្សាឌីយ៉ា(ទំ.១៤៥)។<br><br>ការបង្ករោគដោយព្រូន(ទំ.១៤០ទៅ១៤៤)(ជំងឺព្រូនជាច្រើន មិនបណ្តាលឲ្យកើត ជងឺរាគទេ)។<br><br>ការបង្ករោគនៅក្រៅពោះវៀន(ការបង្ករោគនៅត្រចៀក ទំ.៣០៩ ការរលាកបំពង់ក ទំ.៣០៩ ជំងឺកញ្រ្ជឹល ទំ.៣១១ ការបង្ករោគនៅផ្លូវទឹកនោម(ទំ.២៣៤)។<br><br>ជំងឺគ្រុនចាញ់(ហ្វាស៊ីប៉ារ៉ូម - នៅប៉ែកខាងអាហ្វ្រិក អាស៊ី និងប៉ាស៊ីហ្វិក ទំ.១៨៦)។<br><br>ការពុលអាហារ(អាហារផ្អូម ទំ.១៣៥) | ជំងឺអេដស៍(ការរាគរយៈពេលយូរ អាចជារោគសញ្ញាដំបូង ទំ.៣៩៩)។<br><br>ការមិនរំលាយអាហារ (ជាពិសេស ចំពោះកុមារ ដែលមានកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ និងមនុស្សធំខ្លះ)។<br><br>ទារកដែលមានការពិបាក ក្នុងការរំលាយអាហារដែលថ្មីចំពោះពួកគេ(ទំ.១៥៤)។<br><br>ការមានប្រតិកម្មទំនាស់ជាមួយអាហារខ្លះ (ដូចជាអាហារសមុទ្ទ ។ល។ ទំ.១៦៦) ជួនកាលជាមួយទឹកដោះគោ ឬទឹកដោះផ្សេងៗទៀត។<br><br>ផលរំខានរបស់ថ្នាំពេទ្យខ្លះ ដូចជា អំពីស៊ីលីន ឬតេត្រាស៊ីលីន(ទំ.៥៨)។<br><br>ថ្នាំបញ្ចុះ ឬរុក្ខជាតិពុលនិងគ្រឿងពុលផ្សេងទៀត។<br><br>ការបរិភោគផ្លែឈើខ្ចីច្រើន ឬអាហារដែលមានជាតិខ្លាញ់ច្រើនពេក។ |

*ការបង្ការជំងឺរាក*

ទោះបីជាជំងឺរាកមានមូលហេតុជាច្រើនយ៉ាងក៏ដោយ មូលហេតុដែលញឹកញាប់ជាងគេបំផុតគឺ**ការបង្ករោគ** និង**ការខ្វះអាហារូបត្ថម្ភ។ ជាមួយនឹងការមានអនាម័យល្អ និងមានចំណីអាហារល្អជំងឺរាកភាគច្រើនអាចបង្ការបាន។** ហើយបើមានការព្យាបាលត្រឹមត្រូវដោយឲ្យ**ផឹកទឹកនិងបរិភោគអាហារឲ្យបានគ្រប់គ្រាន់** នោះនឹងមិនសូវមានកុមារស្លាប់ដោយសារជំងឺរាកទេ។




*វដ្តនៃការខ្វះអាហារូបត្ថម្ភ និងជំងឺរាក បានសម្លាប់កុមារជាច្រើន។*

កុមារដែលមានកង្វះអាហារូបត្ថម្ភ តែងតែមានជំងឺរាក ហើយស្លាប់ច្រើនជាងកុមារដែលមានអាហារូបត្ថម្ភល្អ។ មិនតែប៉ុណ្ណោះ ជំងឺរាកអាចជាផ្នែកមួយនៃមូលហេតុនៃការខ្វះអាហារូបត្ថម្ភ។ ហើយបើកំពុងតែមានការខ្វះអាហារូបត្ថម្ភស្រាប់ នោះជំងឺរាកនឹងធ្វើឲ្យបញ្ហានេះមានសភាពកាន់តែធ្ងន់ធ្ងរឡើងថែមទៀត។

| |
|---|
| **ការខ្វះអាហារូបត្ថម្ភបណ្ដាលឲ្យកើតជំងឺរាក ។ ជំងឺរាកបណ្ដាលឲ្យមានការខ្វះអាហារូបត្ថម្ភ។** |

បញ្ហានេះបង្កើតបានជាវដ្តមួយ ដែលក្នុងនោះ បញ្ហាមួយបានធ្វើឲ្យបញ្ហាមួយទៀតមានសភាព កាន់តែធ្ងន់ធ្ងរឡើងថែមទៀត។ ដោយហេតុនេះហើយ អាហារូបត្ថម្ភល្អ មានសារសំខាន់ទាំងក្នុងការបង្ការ និងក្នុងការព្យាបាលជំងឺរាក។

| |
|---|
| **បង្ការជំងឺរាកដោយបង្ការការខ្វះអាហារូបត្ថម្ភ។ បង្ការការខ្វះអាហារូបត្ថម្ភដោយបង្ការជំងឺរាក។** |

ដើម្បីសិក្សាអំពីប្រភេទអាហារដែលជួយរាងកាយទប់ទល់ ឬប្រឆាំងនឹងជំងឺផ្សេងៗ ដូចជំងឺរាក អានជំពូកទី១១។

វិធីបង្ការជំងឺរាក គឺពឹងផ្អែកលើ ទាំង**ការបរិភោគអាហារត្រឹមត្រូវ** និងទាំងការមានអនាម័យល្អ។ សំណូមពរជាច្រើនអំពី**អនាម័យផ្ទាល់ខ្លួន** និងអនាម័យសាធារណៈ មានរៀបរាប់នៅក្នុងជំពូកទី១២។ នៅក្នុងនោះ រួមមានទាំងការប្រើប្រាស់បង្គន់ សារសំខាន់នៃ**ទឹកស្អាត** និងការ**ការពារអាហារ** ពីភាពកខ្វក់ និងពីសត្វរុយ។

ខាងក្រោមគឺជាសំណូមពរសំខាន់ៗផ្សេងទៀតមួយចំនួន សម្រាប់ការពារទារកពីជំងឺរាក ៖

- **បំបៅកុមារដោយទឹកដោះម្ដាយ ជាជាងដោយទឹកដោះគោ។** ឲ្យទារកបៅដោះម្ដាយតែមួយមុខគត់ក្នុងរយៈពេល៦ខែដំបូង។ ទឹកដោះម្ដាយជួយទារកប្រឆាំងនឹងការបង្ករោគផ្សេងៗ ដែលបណ្ដាលឲ្យមានជំងឺរាក។ បើមិនអាចបំបៅទារកដោយទឹកដោះម្ដាយបាន បញ្ចុកទឹកដោះម្ដាយដល់ទារកដោយប្រើពែងនិងស្លាបព្រា។ **មិនត្រូវប្រើដបដើម្បីបំបៅទារកទេ** ព្រោះវាមានការពិបាកក្នុងការរក្សាភាពស្អាត ហើយវាងាយបណ្ដាលឲ្យមានការបង្ករោគផ្សេងៗ។




- នៅពេលអ្នកចាប់ផ្ដើមផ្ដល់អាហារថ្មី ឬអាហាររឹងដល់ទារក ចាប់ផ្ដើមផ្ដល់តែបន្តិចបន្តួចសិន ដោយកិនឲ្យហ្មត់ ហើយលាយវាជាមួយទឹកដោះម្ដាយបន្តិច។ ទារកត្រូវការរៀនរំលាយអាហារថ្មីៗ។ បើទារកចាប់ផ្ដើមទទួលអាហារថ្មី ច្រើនក្នុងពេលតែម្ដង នោះទារកអាចកើតមានជំងឺរាក។ **មិនត្រូវបញ្ឈប់ការបំបៅដោះកូនភ្លាមៗនោះឡើយ។ ចាប់ផ្ដើមឲ្យអាហារផ្សេងទៀត នៅពេលដែលទារកនៅបន្តបៅដោះម្ដាយ។**
- រក្សាអនាម័យដល់ទារក និងដាក់ទារកនៅកន្លែងដែលស្អាត។ ការពារមិនឲ្យទារកដាក់វត្ថុកខ្វក់ចូលក្នុងមាត់របស់វា។
- មិនត្រូវផ្ដល់ថ្នាំផ្សេងៗ ដែលមិនចាំបាច់ ដល់ទារក។




*ការបំបៅកូនដោយទឹកដោះម្ដាយ អាចបង្ការ ជំងឺរាក*

*ការព្យាបាលជំងឺរាក ៖*

**ចំពោះករណីជាច្រើននៃជំងឺរាក គេពុំចាំបាច់ប្រើថ្នាំទេ។** បើរាកធ្ងន់ធ្ងរ គ្រោះថ្នាក់ដែលធំបំផុតគឺ**ការខ្សោះជាតិទឹក**។ បើរាកយូរថ្ងៃ គ្រោះថ្នាក់ធំបំផុត គឺការ**ខ្វះអាហាររូបត្ថម្ភ**។ ដូច្នេះ ផ្នែកដែលសំខាន់ជាងគេបំផុតនៃការព្យាបាល គឺ**ការផ្តល់ជាតិទឹក និងអាហារឲ្យគ្រប់គ្រាន់**។ ចំពោះជំងឺរាក ទោះបីជាបណ្តាលមកពីមូលហេតុអ្វីក៏ដោយ ត្រូវយកចិត្តទុកដាក់ដូចខាងក្រោម ៖

១. បង្ការ ឬគ្រប់គ្រងការខ្សោះជាតិទឹក ៖ អ្នកដែលមានជំងឺរាក ត្រូវផឹកទឹកឲ្យបានច្រើន។ បើរាកខ្លាំង ឬមានរោគសញ្ញានៃការខ្សោះជាតិទឹក ឲ្យគាត់ផឹកទឹកអូរ៉ាលីត( ទំ.១៥២ ) បើទោះជាគាត់មិនចង់ផឹកក៏ដោយ ជំរុញគាត់ឲ្យផឹកទឹកនេះឲ្យបានច្រើន។ ឲ្យគាត់ខំលេបទឹកឲ្យបានច្រើនដងនៅរៀងរាល់ ២ឬ៣នាទីម្តង។

២. បំពេញតម្រូវការអាហាររូបត្ថម្ភរបស់គាត់ ៖ **អ្នកដែលមានជំងឺរាកត្រូវការចំណីអាហារតាមដែលគេអាច ទទួលទានបាន។** នេះជាការសំខាន់ណាស់ ជាពិសេសចំពោះកុមារតូចៗ ឬមនុស្សណាដែលកំពុងមានកង្វះអាហាររូបត្ថម្ភស្រាប់។ ម៉្យាងទៀត នៅពេលដែលមានជំងឺរាក ចំណីអាហារឆ្លងកាត់ក្នុងពោះវៀនយ៉ាងលឿន ហើយមិនបានប្រើប្រាស់ទេ។ **ដូច្នេះ ឲ្យអ្នកជំងឺរាកបរិភោគឲ្យបានច្រើនដងក្នុងមួយថ្ងៃ** ជាពិសេសបើគាត់បរិភោគម្តងៗ បានតែបន្តិចបន្តួច។

- ទារកដែលមានរាក ត្រូវតែ**បន្តការបំបៅដោះ**។
- កុមារដែលស្គម ត្រូវតែបរិភោគឲ្យបានច្រើននូវអាហារថាមពល និងអាហារសាងសង់( ប្រូតេអ៊ីន ) នៅពេលដែលកុមារនោះមានជំងឺរាក ហើយត្រូវទទួលអាហារបន្ថែមនៅពេលដែលគេបានធូរស្បើយ។ ប្រសិនបើកុមារនោះឈប់បរិភោគ ដោយសារមានជំងឺធ្ងន់ ឬក្អួត គាត់គួរចាប់ផ្តើមបរិភោគអាហារភ្លាមនៅពេលដែលគាត់អាចបរិភោគបាន។ **ការឲ្យទឹកអូរ៉ាលីត ក៏ជួយឲ្យកុមារអាចបរិភោគអាហារបានដែរ។** បើទោះជាការផ្តល់អាហារអាចបណ្តាលឲ្យកុមារជុះកាន់តែញឹកញាប់ នៅគ្រាដំបូងក៏ដោយ ក៏វាអាចជួយសង្គ្រោះជីវិតកុមារ នោះដែរ។
- បើកុមារដែលស្គមមានជំងឺរាកជាច្រើនថ្ងៃ ឬនៅតែបន្តរាកតទៅទៀត ផ្តល់អាហារដល់កុមារនោះឲ្យបានកាន់តែញឹកញាប់ យ៉ាងតិច៥ទៅ៦ដងក្នុងមួយថ្ងៃ។ ភាគច្រើន គេមិនចាំបាច់ព្យាបាលតាមវិធីផ្សេងទៀតទេ។

| **អាហារសម្រាប់អ្នកជំងឺរាក** | | |
|---|---|---|
| បើអ្នកជំងឺរាក កំពុងមានក្អួត ឬមានសភាពធ្ងន់ធ្ងរដែលមិនអាចបរិភោគបាន គាត់គួរផឹក ៖ | នៅពេលដែលអ្នកជំងឺនោះអាចបរិភោគបានភ្លាម ជាការបន្ថែមទៅលើជាតិទឹកដែលបានរៀបរាប់នៅខាងឆ្វេងនេះ គេគួរជ្រើសរើសអាហារមួយឬអាហារដែលស្រដៀងគ្នាដូចខាងក្រោម៖ | |
| | **អាហារថាមពល** | **អាហារស្ថាបនារាងកាយ** |
| ទឹកតែ ទឹកបបរ ទឹកបបរដំឡូង ទឹកបបរពោត ទឹកស៊ុបមាន់ សាច់ជ្រូកឬទឹកសណ្តែក | ចេកទុំនៅ ឬឆ្អិន បាយ | សាច់មាន់( ស្ងោរ ឬអាំង ) ស៊ុត( ស្ងោរ ) |
| **ទឹកអូរ៉ាលីត** | គ្រាប់ធញ្ញជាតិចំអិនយ៉ាងល្អ | សាច់( ចំអិនឲ្យឆ្អិនល្អ និងមិនសូវមានខ្លាញ់ ) |
| ទឹកដោះម្តាយ | ពោតឆ្អិនដែលកិនយ៉ាងម៉ត់ ដំឡូងល្ហុងទុំ | សណ្តែក សណ្តែកបារាំង( ចំអិនឲ្យល្អ ហើយកិនឲ្យហ្មត់ ) |
| | ( បើបន្ថែមស្ករ ឬប្រេងបន្លែ ទៅក្នុងអាហារធញ្ញជាតិទាំងនេះ កាន់តែប្រសើរ ) | ត្រី( ចំអិនឲ្យល្អ ) |
| | | ទឹកដោះគោ( ជួនកាលទឹកដោះគោអាចធ្វើឲ្យមានបញ្ហាផ្សេងៗ មើលទំព័របន្ទាប់ ) |
| **មិនត្រូវបរិភោគ ឬផឹក** | | |
| អាហារដែលមានខ្លាញ់ច្រើន ផ្លែឈើនៅមួយចំនួន | ថ្នាំបញ្ចុះគ្រប់ប្រភេទ | អាហារដែលមានជាតិគ្រឿងច្រើនមុខ ស្រា |

## ជំងឺរាក និងទឹកដោះ

**ទឹកដោះម្ដាយ** គឺជាអាហារដ៏ប្រសើរបំផុតសម្រាប់ទារក។ វាជួយការពារនិងប្រឆាំងជំងឺរាក។ **បន្តបំបៅទឹកដោះម្ដាយនៅពេលទារកមានរាក។** វាមិនបណ្ដាលឲ្យទារករាកទេ តែវាជួយទារកឲ្យឆាប់ជាសះស្បើយ។

**ទឹកដោះគោ ម្សៅទឹកដោះ ឬទឹកដោះគោកំប៉ុង** អាចជាប្រភពដ៏ល្អនៃថាមពល និងប្រូតេអ៊ីន។ បន្តផ្ដល់វាដល់កុមារដែលមានរាក។ ចំពោះកុមារមួយចំនួនតូច ទឹកដោះគោទាំងនេះអាចបណ្ដាលរាកកាន់តែខ្លាំង។ បើមានបញ្ហានេះកើតឡើង សាកល្បងបន្ថយទឹកដោះគោនេះ និងលាយវាជាមួយអាហារដ៏ទៃទៀត។ ប៉ុន្តែ គួរចងចាំថា ៖ **កុមារដែលខ្វះអាហាររូបត្ថម្ភ ហើយមានជំងឺរាក ត្រូវការអាហារថាមពល និងអាហារដែលមានប្រូតេអ៊ីនគ្រប់គ្រាន់។** ប្រសិនបើបន្ថយទឹកដោះគោ គួរបន្ថែមអាហារឆ្អិន ដែលកិនឲ្យម៉ត់ ដូចជា សាច់មាន់ ស៊ុត(ក្រហម) សាច់ ត្រីនិងសណ្ដែក។ សណ្ដែកជាអាហារដែលងាយរំលាយ បើគេបកសំបកហើយស្ងោរឲ្យឆ្អិន និងកិនឲ្យម៉ត់។

តាមធម្មតា នៅពេលកុមារបានធូរស្រាលហើយ គាត់នឹងអាចឲ្យផឹកទឹកដោះគោបានច្រើនដោយមិនធ្វើឲ្យរាកទេ។

## ថ្នាំសម្រាប់ព្យាបាលជំងឺរាក

**ចំពោះករណីភាគច្រើននៃជំងឺរាក គេមិនចាំបាច់ប្រើថ្នាំទេ។** ប៉ុន្តែចំពោះករណីខ្លះ ការប្រើថ្នាំដែលត្រឹមត្រូវអាចមានសារសំខាន់។ ទោះជាយ៉ាងណាក៏ដោយ  ក៏មានថ្នាំជាច្រើនដែលគេប្រើជាញឹកញាប់សម្រាប់ព្យាបាលជំងឺរាកអាចមានប្រសិទ្ធភាពបន្តិចបន្តួច ឬគ្មានប្រសិទ្ធភាព។ ថ្នាំខ្លះក្នុងចំណោមថ្នាំទាំងនោះ អាចធ្វើឲ្យមានគ្រោះថ្នាក់ ៖

**ជាទូទៅ ដើម្បីជាការល្អប្រសើរ គួរកុំប្រើថ្នាំដូចខាងក្រោមនេះសម្រាប់ព្យាបាលជំងឺរាក ៖**

"ថ្នាំបំបាត់រាក" ដូចជាថ្នាំដែលមានកៅឡាំង និងប៉ិចទីន(Kaolin & Pectin) (កៅប៉ិចតាតKaopectate ទំ.៣៨៤) ធ្វើឲ្យលាមកខាប់ និងរង្វើល។ ប៉ុន្តែ ថ្នាំនេះមិនអាចបំបាត់ការខ្សោះជាតិទឹក ឬមិនអាចព្យាបាលការបង្ករោគទេ។ ថ្នាំបំបាត់រាកមួយចំនួនដូចជា ឡូប៉េរ៉ាមីត(loperamide) (អ៊ីម៉ូយ៉ូម Imodium) ឬ ឌីហ្វេណុកស៊ីឡាត(diphenoxylate) (ឡូម៉ូទីល lomotil) អាចធ្វើឲ្យមានគ្រោះថ្នាក់ ឬធ្វើឲ្យការបង្ករោគអូសបន្លាយកាន់តែយូរ។



"ថ្នាំបំបាត់រាក" ធ្វើសកម្មភាពដូចជាឆ្នុក។ វាទប់សារធាតុបង្ករោគដែលត្រូវបញ្ចេញមកក្រៅ។



**ថ្នាំបំបាត់រាក ដែលផ្សំជាមួយ ណេអូមីស៊ីន**(neomycin) **ឬស្រ្តិបតូមីស៊ីន**(streptomycin) មិនគួរប្រើទេ។ វាអាចធ្វើឲ្យក្រហាយដល់ពោះវៀន ហើយតែងតែធ្វើឲ្យមានគ្រោះថ្នាក់ច្រើនជាងមានប្រយោជន៍។

**ថ្នាំអង់ទីប៊ីយ៉ូទិក ដូចជា អំពីស៊ីលីន និងតេត្រាស៊ីគ្លីន** មានប្រយោជន៍តែក្នុងករណីជំងឺរាក**មួយចំនួនប៉ុណ្ណោះ** (មើលទំ.១៥៨)។ ប៉ុន្តែ ជួនកាល ថ្នាំទាំងនេះ អាចបណ្ដាលឲ្យរាកបាន ជាពិសេសចំពោះកុមារតូចៗ។ ប្រសិនបើ បន្ទាប់ពីបានប្រើអង់ទីប៊ីយ៉ូទិករយៈពេលពីរបីថ្ងៃ ហើយរាកកាន់តែខ្លាំងឡើង ឈប់ប្រើវា ព្រោះថ្នាំអង់ទីប៊ីយ៉ូទិកនោះអាចជាមូលហេតុដែលនាំឲ្យរាក។

**ខ្លរ៉ាំហ្វេនីកុល**(chloramphenicol) មានគ្រោះថ្នាក់ខ្លះ ក្នុងការប្រើប្រាស់វា (មើលទំ.៣៥៧) ហើយមិនគួរប្រើវាសម្រាប់ព្យាបាលជំងឺរាកកម្រិតស្រាល ឬប្រើទៅលើទារកដែលមានអាយុតិចជាងមួយខែ។

**ថ្នាំបញ្ចុះ** គេមិនត្រូវប្រើថ្នាំបញ្ចុះចំពោះមនុស្សកំពុងរាកទេ។ វានឹងធ្វើឲ្យរាកកាន់តែខ្លាំង ហើយអាចបង្កើនគ្រោះថ្នាក់នៃការខ្សោះជាតិទឹកទៀតផង។

### វិធីព្យាបាលពិសេសចំពោះករណីជំងឺរាកផ្សេងៗ

ខណៈពេលដែលមានករណីជំងឺរាកជាច្រើនត្រូវបានព្យាបាលយ៉ាងមានប្រសិទ្ធភាព ដោយការផ្តល់**ជាតិទឹក** និង**អាហារ**ឲ្យបានច្រើន និង**មិនបាច់ប្រើថ្នាំពេទ្យ**ក៏ពិតមែន ក៏មានពេលខ្លះ គេក៏ត្រូវការការព្យាបាលពិសេសដែរ។

ក្នុងការពិចារណាអំពីការព្យាបាលនេះ គួរចងចាំថា មានករណីនៃជំងឺរាកមួយចំនួន ជាពិសេសចំពោះកុមារតូចៗ បណ្តាលមកពីមានការបង្ករោគ**នៅខាងក្រៅពោះវៀន**។ គួរពិនិត្យរកការបង្ករោគ**នៅត្រចៀក បំពង់ក** និង**ប្រពន្ធ័ទឹកនោម**ជានិច្ច។ បើរកឃើញថាមាន គួរព្យាបាលការបង្ករោគទាំងនេះ។ ម្យ៉ាងទៀត ក៏គួរពិនិត្យរកមើលរោគសញ្ញានៃជំងឺ**កញ្ជ្រឹល**ផងដែរ។

បើកុមារមានរាកកម្រិតស្រាលរួមជាមួយនឹងមានរោគសញ្ញាផ្តាសាយ ជំងឺរាកនោះអាចបណ្តាលមកពីវីរុស នោះគេមិនត្រូវការការព្យាបាលពិសេសទេ។ ឲ្យផឹកទឹកឲ្យបានច្រើននិងផ្តល់អាហារដែលកុមារនោះអាចបរិភោគបាន។

ចំពោះករណីពិបាកមួយចំនួននៃជំងឺរាក ការវិភាគពិនិត្យលាមក ឬការធ្វើតេស្តផ្សេងៗអាចជាការចាំបាច់ ដើម្បីដឹងពីវិធីព្យាបាល វាឲ្យបានត្រឹមត្រូវ។ ប៉ុន្តែតាមធម្មតាគេអាចដឹងបានតាមរយៈការសាកសួរសំនួរជាក់លាក់មួយចំនួន ការមើលលាមក និងការរកមើលរោគសញ្ញាសំខាន់ៗខ្លះ។ ខាងក្រោមគឺជាសេចក្តីណែនាំខ្លះៗសម្រាប់ការព្យាបាលទៅតាមរោគសញ្ញាផ្សេងៗ។

១. **រាកកម្រិតស្រាល ដែលកើតឡើងភ្លាមៗ ដោយគ្មានគ្រុនក្តៅ** (ឈឺក្រពះ ? វីរុស ? )

- ផឹកទឹកឲ្យបានច្រើន។ តាមធម្មតា គេមិនត្រូវការការព្យាបាលពិសេសទេ។ ជាទូទៅ គេមិនចាំបាច់ប្រើថ្នាំផ្អកបំបាត់រាកទេ ដូចជា កៅឡាំងជាមួយនឹងប៉ិចទីន (កៅប៉ិចតាតKaopectate ទំ.៣៨៤) ឬឌីហ្វេណុកស៊ីឡាត (Diphenoxylate ឡូម៉ូទីល lomotil)នោះឡើយ។ ជាទូទៅ ថ្នាំទាំងនេះតែងតែមិនចាំបាច់ និងមិនអាចជួយកែតម្រូវការខ្សោះជាតិទឹក ឬសម្លាប់មេរោគបានឡើយ ដូច្នេះគេមិនចាំបាច់ចំណាយលុយដើម្បីទិញវានោះទេ។ គេមិនត្រូវឲ្យថ្នាំទាំងនោះដល់អ្នកជំងឺធ្ងន់ៗ ឬកុមារតូចៗទេ។

២. **រាករួមជាមួយក្អួត** (មានមូលហេតុច្រើនយ៉ាង)



- បើកុមារដែលរាកមានក្អួតផងនោះ គ្រោះថ្នាក់នៃការខ្សោះជាតិទឹកមានកាន់តែខ្លាំង ជាពិសេសចំពោះកុមារតូចៗ។ ជាការសំខាន់ណាស់ គឺត្រូវឲ្យកុមារផឹកទឹកអូរ៉ាលីត (ទំ.១៥២) ទឹកតែ ទឹកស៊ុប ឬទឹកផ្សេងៗទៀតដែលគេផឹកបាន។ **បន្តឲ្យទឹកទាំងនេះជានិច្ច ទោះបីជាគេក្អួតចេញមកវិញក៏ដោយ។** ទឹកមួយចំនួននឹងនៅសល់ក្នុងខ្លួន។ ឲ្យគេផឹកនៅរៀងរាល់ ៥ទៅ១០នាទីម្តង។
- បើអ្នកមិនអាចគ្រប់គ្រងការក្អួតបាន ឬប្រសិនបើការខ្សោះជាតិទឹកកាន់តែខ្លាំងឡើង ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

៣. **រាកមានលាយសំបោរនិងឈាម។ ច្រើនតែរ៉ាំរ៉ៃ។ គ្មានគ្រុនក្តៅ មានថ្ងៃខ្លះមានរាក និងថ្ងៃខ្លះទៀត មានទល់លាមក។** (នោះអាចជាជំងឺរាកមួលដែលបង្កឡើងដោយពពួកអាមីប។ សម្រាប់ព័ត៌មានលំអិតមើលទំ.១៤៤)

- ប្រើថ្នាំមីត្រូនីដាហ្សូល(Metronidazole ទំ.៣៦៩)។ ប្រើថ្នាំនេះទៅតាមកម្រិតវេជ្ជបញ្ជារបស់គ្រូពេទ្យ។ ប្រសិនបើជំងឺរាកនៅតែមានបន្ទាប់ពីទទួលការព្យាបាល ពិគ្រោះយោបល់ជាមួយគ្រូពេទ្យ។

៤. **រាកធ្ងន់ធ្ងរមានលាយឈាម និងគ្រុនក្តៅ** (រាកមួលដែលបង្កដោយបាក់តេរីស៊ីហ្សែលឡា)

- ឲ្យថ្នាំស៊ីប្រូហ្លកសាស៊ីន( Ciprofloxacin )ទៅមនុស្សធំ តែមួយដូស : ១ក្រ. លេបតាមមាត់។ ប៉ុន្តែ មិនគួរប្រើថ្នាំនេះជាមួយស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម១៨ឆ្នាំទេ។ ( ចំពោះកុមារដែលមានអាយុក្រោម៨សប្តាហ៍ ស្វែងរកជំនួយពីគ្រូពេទ្យ )។ ជាញឹកញាប់ មេរោគស៊ីហ្សែលឡាមានភាពស៊ាំជាមួយនឹងអំពីស៊ីលីន( Ampicillin ទំ.៣៥៣ ) និងកូទ្រីម៉ុកសាសូល( Cotrimoxazole ទំ.៣៥៨ ) ប៉ុន្តែថ្នាំទាំងនេះនៅតែត្រូវបានប្រើនៅឡើយ។ ប្រសិនបើថ្នាំទីមួយដែលអ្នកបានប្រើ មិនបានធ្វើឲ្យមានការធូរស្រាលក្នុងរយៈពេលពីរថ្ងៃ សាកល្បងប្រើថ្នាំមួយទៀត ឬស្វែងរកជំនួយពីគ្រូពេទ្យ។ ស្ត្រីមានផ្ទៃពោះ៦ខែ មិនគួរប្រើថ្នាំកូទ្រីម៉ុកសាសូលទេ( ទំ.៣៥៩ )។ ថ្នាំអាស៊ីត្រូមេស៊ីន( Azithromycin )ក៏មានប្រសិទ្ធិភាពដែរ ហើយមានសុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះនិងកុមារ។ សម្រាប់មនុស្សធំ ឲ្យថ្នាំលេបតាមមាត់៥០០ម.ក្រនៅថ្ងៃទី១ និង២៥០ម.ក្រមួយថ្ងៃម្តង រយៈពេល៤ថ្ងៃ។ ចំពោះកម្រិតប្រើសម្រាប់កុមារ ពិភាក្សាជាមួយបុគ្គលិកសុខាភិបាល។

### ៥. **រាកធ្ងន់ធ្ងរមានគ្រុនក្តៅ ដែលជាទូទៅគ្មានលាយឈាម**

- គ្រុនក្តៅអាចបណ្តាលមកពីការខ្សោះជាតិទឹក។ ឲ្យផឹកទឹកអ៊ូរ៉ាលីតឲ្យបានច្រើន( ទំ.១៥២ )។ ប្រសិនបើអ្នកជំងឺមិនបានធូរស្រាលក្នុងរវាង៦ម៉ោងបន្ទាប់ពីចាប់ផ្តើមព្យាបាលដោយទឹកអ៊ូរ៉ាលីត ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។
- ពិនិត្យរកមើលរោគសញ្ញានៃជំងឺគ្រុនពោះវៀន។ បើមាន ចាប់ផ្តើមព្យាបាលជំងឺគ្រុនពោះវៀន( មើលទំ.១៨៨ )។
- នៅតំបន់ដែលច្រើនមានជំងឺគ្រុនចាញ់ដោយ***ហ្វាល់ស៊ីប៉ារ៉ូម*** ព្យាបាលរាល និងគ្រុនក្តៅនៃជំងឺគ្រុនចាញ់ ( មើលទំ. ១៨៧ ) ជាពិសេសបើគេមានអណ្តើករីកធំ។

### ៦. **រាកដែលមានលាមកពណ៌លឿង ក្លិនអាក្រក់ មានពពុះៗ គ្មានលាយឈាមឬសំបោរ**

- ជាញឹកញាប់អ្នកជំងឺនោះមានខ្យល់ជាច្រើននៅក្នុងពោះ ហើយភើចេញមកមានក្លិនអាក្រក់ ដូចជាស្ពាន់ធ័រ។
- នេះអាចបង្កឡើងដោយពពួកមេរោគប៉ារ៉ាស៊ីតតូចៗ ឈ្មោះថាហ្សាឌីយ៉ា( មើលទំ.១៤៥ ) ឬអាចបណ្តាលមកពីការខ្វះអាហាររូបត្ថម្ភ។ ក្នុងករណីណាមួយក៏ដោយ ការផឹកទឹកឲ្យបានច្រើន ការបរិភោគអាហារបំប៉នឲ្យបានគ្រប់គ្រាន់ និងសម្រាក គឺជាការព្យាបាលតែមួយគត់ដែលចាំបាច់។ ការបង្ករោគធ្ងន់ធ្ងរដោយហ្សាឌីយ៉ា អាចព្យាបាលដោយប្រើថ្នាំមីត្រូនីដាហ្សូល( Metronidazole ទំ.៣៦៩ )។ ថ្នាំគីណាគ្រីន( Quinacrine ***អាតាប្រីន Atabrine*** ) មានតម្លៃថោកជាង តែវាមានផលរំខានធ្ងន់ធ្ងរជាង( ទំ.៣៧០ )។

### ៧. **រាករុំរ៉ៃ (រាករយៈពេលយូរ ឬរាកដែលបន្តកើតឡើងវិញ)**

- នេះអាចបណ្តាលមកពីការខ្វះអាហាររូបត្ថម្ភ ឬដោយសារមានការបង្ករោគរុំរ៉ៃ ដូចជាការបង្ករោគដោយអាមីប ឬហ្សាឌីយ៉ា។ ឲ្យកុមារបរិភោគអាហារបំប៉នឲ្យបានច្រើនដងក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃ( ទំ.១១០ )។ ប្រសិនបើជំងឺរាកនៅតែបន្ត ស្វែងរកជំនួយពីគ្រូពេទ្យ។

### ៨. **រាកដូចទឹកអង្ករ (អាសន្នរោគ)**

- ការរាកមានលាមកដូចទឹកអង្ករ ក្នុងបរិមាណច្រើន អាចជារោគសញ្ញានៃជំងឺអាសន្នរោគ។ នៅក្នុងប្រទេសដែលមានជំងឺប្រកបដោយគ្រោះថ្នាក់កើតឡើង ជំងឺអាសន្នរោគតែងតែមានការឆ្លងរាតត្បាត ហើយជាធម្មតាវា ច្រើនតែមានសភាពធ្ងន់ធ្ងរចំពោះក្មេងជំទង់ និងមនុស្សចាស់។ ការខ្សោះជាតិទឹកធ្ងន់ធ្ងរអាចកើតមានយ៉ាងលឿន ជាពិសេសបើមានក្អួតផងនោះ។ ព្យាបាលការខ្សោះជាតិទឹកឲ្យបានជាប់( មើលទំ.១៥២ ) ហើយឲ្យថ្នាំដុកស៊ីស៊ីគ្លីន ( Doxycycline ) ឬតេត្រាស៊ីគ្លីន( Tetracycline ទំ.៣៥៦ ) ឬអេរីត្រូមីស៊ីន( Erythromycin ) ដល់កុមារ ( ទំ.៣៥៣ )តែក្នុងករណីធ្ងន់ធ្ងរប៉ុណ្ណោះ។ បើមានជំងឺអាសន្នរោគ ត្រូវរាយការណ៍ដល់អជ្ញាធរសុខាភិបាល ហើយត្រូវស្វែងរកជំនួយពីគ្រូពេទ្យ។

*គេអាចធ្វើគ្រែរបៀបនេះសម្រាប់ដាក់អ្នកជំងឺអាសន្នរោគដែលមានរាក ធ្ងន់ធ្ងរ។ ពិនិត្យមើលចំណុះទឹកដែលអ្នកជំងឺបាត់បង់ ហើយត្រូវ ប្រាកដថាត្រូវឲ្យគាត់ផឹកទឹកអ៊ូរ៉ាលីតឲ្យបានច្រើន។ ត្រូវឲ្យ គាត់ផឹក ទឹកនេះជាបន្តរហូតហើយឲ្យគាត់ផឹកតាមដែលគាត់អាចផឹកបាន។*



# ការថែទាំទារកដែលមានជំងឺរាក

ជំងឺរាកតែងតែមានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះទារក និងកុមារតូចៗ។ ជាទូទៅ គេមិនចាំបាច់ប្រើថ្នាំពេទ្យទេ ប៉ុន្តែគេត្រូវផ្តល់ការថែទាំពិសេស ព្រោះទារកអាចស្លាប់យ៉ាងលឿន ដោយសារការខ្សោះជាតិទឹក។

*បំបៅទារកដោយទឹកដោះម្តាយ*



- **បន្តបំបៅដោះម្តាយ**និង**ឲ្យទឹកអូ៉រ៉ាលីត**បន្តិចម្តងៗ។
- ប្រសិនបើការក្អួតចោទជាបញ្ហា ឲ្យបៅដោះឲ្យបានញឹកញាប់ ប៉ុន្តែម្តងបន្តិចៗ ប៉ុណ្ណោះ។ ឲ្យផឹកទឹកអូ៉រ៉ាលីតម្តងបន្តិចៗ រៀងរាល់ ៥ទៅ១០នាទីម្តង ផងដែរ (មើលការក្អួតទំ.១៦១)។
- បើគ្មានទឹកដោះម្តាយទេ ព្យាយាមបញ្ចុកទឹកដោះផ្សេងៗទៀតឲ្យបានញឹកញាប់ ឬទឹកដោះជំនួស (ទឹកសណ្តែកសៀង) **លាយជាមួយទឹកឆ្អិនពីរភាគ**។ បើទឹកដោះហាក់ដូចជាធ្វើឲ្យរាកកាន់តែខ្លាំង ឲ្យជាតិប្រូតេអ៊ីនផ្សេងទៀតខ្លះ (ដូចជា សាច់មាន់កិនឲ្យហ្មត់ ស៊ុត សាច់គ្មានខ្លាញ់ ឬសណ្តែកដែលគ្មានសំបកកិនលាយជាមួយស្ករ ឬបាយដែលឆ្អិនល្អ ឬអាហារផ្សេងទៀតដែលមានជាតិផ្អែម និងទឹកឆ្អិន)។

*ហើយ ឲ្យគេសជ្ជៈបង្គ្រប់ជាតិទឹកផងដែរ*



- បើកុមារមានអាយុតិចជាងមួយខែ ព្យាយាមស្វែងរកជំនួយពីគ្រូពេទ្យសិនមុនពេលធ្វើការផ្តល់ថ្នាំពេទ្យអ្វីមួយដល់កុមារនោះ។ ប្រសិនបើគ្មានភ្នាក់ងារសុខាភិបាលទេ ហើយកុមារនោះឈឺធ្ងន់ ឲ្យថ្នាំទឹកស៊ីរ៉ូសម្រាប់កុមារ ដែលមានថ្នាំអំពីស៊ីលីន កន្លះស្លាបព្រាកាហ្វេ ៤ដង ក្នុងមួយថ្ងៃ(មើលទំ.៣៥៣)។ ដើម្បីជាការប្រសើរ មិនត្រូវប្រើអង់ទីប៊ីយ៉ូទិកផ្សេងទៀតទេ។

# ពេលដែលត្រូវស្វែងរកជំនួយពីគ្រូពេទ្យ ក្នុងករណីជំងឺរាក

ជំងឺរាក និងរាកមួលអាចមានគ្រោះថ្នាក់យ៉ាងខ្លាំង ជាពិសេសចំពោះកុមារតូចៗ។ **ក្នុងស្ថានភាពដូចខាងក្រោម អ្នកគួរស្វែងរកជំនួយពីគ្រូពេទ្យ ៖**

- បើការរាកលើសពី៤ថ្ងៃ ហើយនៅតែគ្មានការធូរស្រាល ឬលើសពីមួយថ្ងៃចំពោះកុមារតូចៗដែលរាកខ្លាំង។
- ប្រសិនបើអ្នកជំងឺមានរោគសញ្ញាខ្សោះជាតិទឹក ហើយកាន់តែធ្ងន់ធ្ងរទៅៗ។
- បើកុមារក្អួតចេញមកវិញអស់នូវអ្វីដែលគេបានផឹកចូល ឬមិនអាចផឹកអ្វីសោះ ឬប្រសិនបើមានក្អួតជាបន្តបន្ទាប់រយៈពេលជាងបីម៉ោង បន្ទាប់ពីចាប់ផ្តើមផឹកទឹកអូ៉រ៉ាលីត។
- ប្រសិនបើកុមារចាប់ផ្តើមប្រកាច់ ឬប្រសិនបើជើងនិងមុខរបស់វាឡើងហើម។
- ប្រសិនបើអ្នកជំងឺនោះមានសភាពធ្ងន់ធ្ងរ ខ្សោយខ្លាំង ឬមានខ្វះអាហាររូបត្ថម្ភ មុនពេលកើតមានជំងឺរាក (ជាពិសេសចំពោះកុមារតូចៗ និងមនុស្សចាស់)។
- ប្រសិនបើមានឈាមច្រើននៅក្នុងលាមក។ នេះអាចបណ្តាលឲ្យមានគ្រោះថ្នាក់ បើទោះជាមានរាកតែបន្តិចបន្តួចក៏ដោយ(មើលអំពីការស្ទះពោះវៀន ទំ.៩៤)។

# ការថែរក្សាអ្នកជំងឺរាកស្រួចស្រាល់

## ជំងឺរាក

តើមានរោគសញ្ញាខ្សោះជាតិទឹកឬទេ? (ទឹកនោមតិចឬគ្មានទឹកនោម ភ្នែករូង បបូរមាត់ស្ងួត)។

- ទេ → បង្ការការខ្សោះជាតិទឹក ៖ ផឹកទឹកឲ្យច្រើន
- បាទ → ព្យាបាលការខ្សោះជាតិទឹក ៖ ផឹកទឹកឲ្យបានច្រើន និងផឹកទឹកអូរ៉ាលីត (ទំ.១៥២)។

→ បង្ការនិងព្យាបាលការខ្វះអាហារូបត្ថម្ភ
ផ្តល់អាហារឲ្យបានឆាប់តាមដែលគាត់អាចបរិភោគបាន។ អាហារកិនឲ្យម៉ត់ គឺជាអាហារប្រសើរបំផុត ពោលគឺផ្តល់អាហារថាមពលរួមជាមួយអាហារទ្រទ្រង់រាងកាយ។ បន្តការបំបៅទឹកដោះម្តាយ។

តើមានគ្រុនក្តៅដែលមានរយៈពេលលើសពី ៦ម៉ោង បន្ទាប់ពីបានព្យាបាលការខ្សោះជាតិទឹកឬទេ?

- ទេ → រាកមានឈាម និងមានសំបោរ
  - បាទ → ឲ្យមីត្រូនីដាហ្សូល (metronidazole) សម្រាប់អាមីប (ទំ. ៣៦៩)
    - ជា
    - មិនជា → រកជំនួយពីគ្រូពេទ្យ
  - ទេ → រាកពណ៌លឿង និងមានពពុះ?
    - បាទ → ឲ្យថ្នាំមីត្រូនីដាហ្សូល ឬ គីណាគ្រីន សម្រាប់ចាឌីយ៉ា (ទំ. ៣៦៩)
      - ជា
      - មិនជា → រកជំនួយពីគ្រូពេទ្យ
    - ទេ → មិនឲ្យថ្នាំ ៖ បន្តផ្តល់ទឹកអូរ៉ាលីត ទឹក និងអាហារ។
      - ជា
      - មិនជា → រកជំនួយពីគ្រូពេទ្យ
- បាទ → ឲ្យអំពីស៊ីលីន (ampicillin ទំ. ៣៥៣) ឬ កូទ្រីម៉ុកសាសូល (cotrimoxazole ទំ. ៣៥៨)
  - ជា
  - មិនជា ក្នុងរយៈពេល៣ថ្ងៃ → តើមានរោគសញ្ញាគ្រុនពោះវៀនឬទេ? (កម្តៅឡើងរាល់ថ្ងៃ ជីពចរដើរយឺត ឈឺធ្ងន់ ទំ. ១៨៨)
    - ទេ → រកជំនួយពីគ្រូពេទ្យ
    - បាទ → បន្តឲ្យកូទ្រីម៉ុកសាសូល (cotrimoxazole) អំពីស៊ីលីន (ampicillin) ខ្លូរ៉ាំហ្វេនីកុល (chloramphenicol) ចំនួន ២សប្តាហ៍ ។
      - ជា
      - មិនជា → រកជំនួយពីគ្រូពេទ្យ



រកជំនួយពីគ្រូពេទ្យ

# ការក្អួត

មនុស្សជាច្រើនជាពិសេសកុមារ ជួនកាលមានការឈឺក្រពះនិងមានក្អួត។ ជាញឹកញាប់គេមិនអាចរកឃើញមូលហេតុរបស់វាទេ។ វាអាចមានការឈឺចាប់បន្តិចបន្តួចក្នុងក្រពះ ឬពោះវៀន ឬមានគ្រុនក្តៅ។ ជាទូទៅ ការក្អួតបែបនេះមិនធ្ងន់ធ្ងរទេ ហើយវានឹងបាត់ទៅវិញដោយខ្លួនឯង។



ការក្អួតគឺជារោគសញ្ញាមួយក្នុងចំណោមសញ្ញាទាំងឡាយនៃបញ្ហាផ្សេងៗជាច្រើន ដែលខ្លះមានសភាពស្រាល និងខ្លះទៀតធ្ងន់ធ្ងរ។ ដូច្នេះគេចាំបាច់ត្រូវធ្វើការពិនិត្យ អ្នកជំងឺនោះដោយយកចិត្តទុកដាក់បំផុត។ ជាញឹកញាប់ ការក្អួតតែងបណ្តាលមកពីបញ្ហាក្រពះ ឬពោះវៀន ដូចជា៖ ការបង្ករោគអ្វីមួយ(អានអំពីជំងឺរាកក្នុងទំ.១៥៣) ការពុលបណ្តាលមកពីអាហារផ្អូម(ទំ.១៣៥) ឬការឈឺពោះស្រួចស្រាល់ ឧទាហរណ៍ ជំងឺរលាកខ្នែងពោះវៀន ឬមានអ្វីស្ទះនៅក្នុងពោះវៀន (ទំ.៩៤)។ ដូចគ្នានេះដែរ ស្ទើរតែគ្រប់ជំងឺទាំងអស់ដែលមានគ្រុនក្តៅឬមានការឈឺចាប់ខ្លាំង អាចបណ្តាលឲ្យក្អួត ជាពិសេស ជំងឺគ្រុនចាញ់(ទំ.១៨៦) ជំងឺរលាកថ្លើម (ទំ.១៧២) ការរលាកសាច់បំពង់ក(ទំ.៣០៩) ការឈឺត្រចៀក (ទំ.៣០៩) ជំងឺរលាកស្រោមខួរក្បាល(ទំ.១៨៥) ការបង្ករោគនៅផ្លូវទឹកនោម(ទំ.២៣៤) ជំងឺថង់ទឹកប្រមាត់(ទំ.៣២៩) ឬជំងឺឈឺក្បាលប្រកាំង(ទំ.១៦២)។

## សញ្ញាគ្រោះថ្នាក់នៃការក្អួត ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់!!

- ការខ្សោះជាតិទឹកដែលចេះតែខ្លាំងឡើងៗ ហើយដែលអ្នកមិនអាចព្យាបាលបាន (ទំ.១៥២)
- ការក្អួតធ្ងន់ធ្ងរដែលអូសបន្លាយលើសពី២៤ម៉ោង
- ការក្អួតយ៉ាងគំហុក ជាពិសេសបើកំអួតមានពណ៌បៃតងចាស់ ពណ៌ត្នោត ឬមានក្លិនស្អុយដូចលាមក (រោគសញ្ញានៃការស្ទះពោះវៀន ទំ.៩៤)។
- មានការឈឺចាប់ជាប់នៅក្នុងពោះវៀន ជាពិសេសបើអ្នកជំងឺមិនអាចបត់ជើងធំ ឬបើអ្នកមិនអាចស្តាប់ឮសំឡេងកូរពោះនៅពេលដែលអ្នកយកត្រចៀកដាក់នៅពោះ (អានអំពីការឈឺពោះស្រួចស្រាល់ ៖ ការស្ទះពោះវៀន ការរលាកខ្នែងពោះវៀន ទំ.៩៤)
- ការក្អួតឈាម (ដំបៅក្រពះ ទំ.១២៨ជំងឺក្រិនថ្លើម ទំ.៣២៨)

## ដើម្បីជួយបំបាត់ការក្អួតធម្មតា ៖



- ♦ កុំបរិភោគអ្វីនៅពេលដែលក្អួតខ្លាំង
- ♦ ក្រេបភេសជ្ជៈកូកា ឬទឹកខ្ញី។ ទឹកតែមួយចំនួនក៏អាចជួយបានដែរ។
- ♦ ចំពោះការខ្សោះជាតិទឹក គេអាចឲ្យក្រេបទឹកកូកា ទឹកតែ ឬទឹកអូ៉រ៉ាលីត(ទំ.១៥២)
- ♦ បើក្អួតមិនបាត់ក្នុងពេលភ្លាមៗទេ ប្រើថ្នាំបញ្ឈប់ក្អួតដូចជា ប្រូមេតាស៊ីន(Promethazine ទំ.៣៨៦) ឬឌីហ្វេនីត្រាមីន(Diphenhydramine ទំ.៣៨៧)។

ភាគច្រើននៃថ្នាំទាំងនេះមានជាថ្នាំគ្រាប់ ស៊ីរ៉ូ ថ្នាំចាក់ និងថ្នាំស៊ុលតាមគូថ។ ថ្នាំគ្រាប់ ឬថ្នាំស៊ីរ៉ូក៏អាចស៊ុលទៅតាមគូថបានដែរ។ កិនគ្រាប់ថ្នាំឲ្យហ្មត់ លាយជាមួយទឹកបន្តិច ហើយដាក់វាចូលទៅក្នុងគូថដោយប្រើស៊ីរ៉ាំងដោយមិនបាច់ប្រើម្ជុល។

នៅពេលលេបថ្នាំតាមមាត់ គួរលេបដោយប្រើទឹកតិចតួចបំផុត ហើយមិនត្រូវលេបអ្វីទៀតក្នុងរយៈពេល៥នាទី។កុំឲ្យលេបលើសកម្រិតណែនាំរបស់គ្រូពេទ្យ។ មិនត្រូវឲ្យលេបថ្នាំជាលើកទីពីរទៀត រហូតពេលដែលការខ្សោះជាតិទឹកត្រូវបានកែតម្រូវ ហើយអ្នកជំងឺ ចាប់ផ្តើមនោម។ បើមានក្អួត និងរាកយ៉ាងខ្លាំងដែលមិនអាចឲ្យអ្នកជំងឺលេបថ្នាំតាមមាត់ ឬបាញ់បញ្ចូលតាមគូថបាន ចាក់ថ្នាំបំបាត់ក្អួតមួយម្ជុល។ ថ្នាំប្រូមេតាស៊ីន អាចមានប្រសិទ្ធភាពយ៉ាងល្អ។ ប្រយត្ន័ មិនត្រូវប្រើថ្នាំច្រើនពេក។

# ការឈឺក្បាល និងជំងឺប្រកាំង

**ការឈឺក្បាលធម្មតា** អាចធូរស្រាលដោយការសម្រាក និងថ្នាំអាស្ពីរីន(Aspirin)។ ការយកក្រណាត់ជ្រលក់ទឹកក្តៅ ស្អំលើកញ្ចឹងក និងការច្របាច់កញ្ចឹងក និងស្មាថ្នមៗក៏អាចជួយបានខ្លះដែរ។ ការព្យាបាលតាមបៀបបុរាណក៏អាចជួយបានដែរ។

*ចំពោះការឈឺក្បាលធម្មតា ជួនកាល ការព្យាបាលតាមបៀបបុរាណក៏អាចមានប្រសិទ្ធភាពដូចថ្នាំពេទ្យដែរ។*




ការឈឺក្បាលកើតមានជាញឹកញាប់ក្នុងជំងឺដែលបណ្តាលឲ្យមានគ្រុនក្តៅ។ បើការឈឺក្បាលមានសភាពធ្ងន់ធ្ងរ ពិនិត្យរកមើលរោគសញ្ញាជំងឺរលាកស្រោមខួរក្បាល (ទំ.១៨៥)។

ការឈឺក្បាលដែលកើតឡើងជាបន្តបន្ទាប់ អាចជារោគសញ្ញានៃជំងឺរ៉ាំរ៉ៃអ្វីមួយ ឬការខ្វះអាហាររូបត្ថម្ភ។ ការបរិភោគអាហារឲ្យបានត្រឹមត្រូវ និងសម្រាកឲ្យបានគ្រប់គ្រាន់គឺជាការសំខាន់។ បើការឈឺក្បាលនៅតែបន្ត ស្វែងរកជំនួយពីគ្រូពេទ្យ។




**ជំងឺឈឺក្បាលប្រកាំង** ៖ គឺជាការឈឺក្បាលពើតៗយ៉ាងខ្លាំងដែលភាគច្រើនឈឺតែមួយចំហៀងក្បាល។ ជំងឺឈឺក្បាលប្រកាំងអាចកើតឡើងជាញឹកញាប់ ឬកើតឡើងដោយមានចន្លោះជាច្រើនខែ ឬច្រើនឆ្នាំ។

ជំងឺប្រកាំងដែលឧស្សាហ៍កើតមាន ចាប់ផ្តើមដោយការស្រវាំងភ្នែក ការមើលឃើញចំនុចពន្លឺចម្លែកៗ ឬការស្ពឹកដៃម្ខាង ឬជើងម្ខាង។ រោគសញ្ញានេះកើតមានបន្ទាប់ពីមានការឈឺក្បាលធ្ងន់ធ្ងរដែលអូសបន្លាយជាច្រើនម៉ោងឬច្រើនថ្ងៃ ហើយភាគច្រើន តែងតែមានក្អួតទៀតផង។ ការឈឺក្បាលប្រកាំង មានការឈឺចាប់ខ្លាំងណាស់ ប៉ុន្តែវាពុំមានគ្រោះថ្នាក់ទេ។

ដើម្បីបញ្ឈប់ការឈឺក្បាលប្រកាំង ព្យាយាមធ្វើដូចខាងក្រោមនេះ នៅពេលមានរោគសញ្ញាដំបូង ៖

- លេបអាស្ពីរីន២គ្រាប់(Aspirin)ជាមួយកាហ្វេខ្មៅ ឬទឹកតែចត់មួយពែង។
- សម្រាកនៅកន្លែងងងឹត និងស្ងាត់។ ព្យាយាមបន្ធូរអារម្មណ៍។ ព្យាយាមឈប់គិតពីបញ្ហាទាំងឡាយរបស់ខ្លួន។
- ចំពោះជំងឺប្រកាំងធ្ងន់ធ្ងរ លេបថ្នាំអាស្ពីរីន ហើយបើអាច ប្រើជាមួយកូដេអ៊ីន(Codeine) ឬប្រើជាមួយថ្នាំងងុយដេកផ្សេងទៀត។ ឬថ្នាំអ៊ែហ្គូតាមីន(Ergotamine) ជាមួយកាហ្វេអ៊ីន(Caffeine) (Cafergotទំ.៣៨០)។ លេបដំបូងពីរគ្រាប់ ហើយលេបមួយគ្រាប់នៅរៀងរាល់ ៣០នាទីម្តង រហូតដល់បាត់ឈឺ។ កុំលេបឲ្យលើសពី៦គ្រាប់ក្នុងមួយថ្ងៃ។




*បំរាម ៖* មិនត្រូវប្រើថ្នាំCafergot នៅពេលមានផ្ទៃពោះទេ។



# គ្រុនផ្ដាសាយ និងផ្ដាសាយធំ



គ្រុនផ្ដាសាយ និងផ្ដាសាយធំគឺជាការបង្ករោគដែលកើតមានជាញឹកញាប់ ដោយសារមេរោគវីរុស ដែលអាចបណ្ដាលឲ្យមានហៀរសំបោរ ក្អក ឈឺបំពង់ក ហើយជួនកាលមានគ្រុនក្ដៅ ឬឈឺសន្លាក់។ វាអាចធ្វើឲ្យមានរាកបន្តិចបន្តួច ជាពិសេសចំពោះកុមារ។

គ្រុនផ្ដាសាយនិងផ្ដាសាយធំតែងតែបាត់ទៅវិញដោយមិនបាច់ប្រើថ្នាំ។ **កុំប្រើថ្នាំប៉េនីស៊ីលីន(Penicillin) និងតេត្រាស៊ីគ្លីន(Tetracyline) ឬពពួកអង់ទីប៊ីយ៉ូទិកដទៃទៀត** ព្រោះវាមិនអាចជួយអ្វីទាំងអស់ ហើយអាចបណ្ដាលឲ្យមានគ្រោះថ្នាក់ទៀតផង។

- ផឹកទឹកឲ្យបានច្រើន និងសម្រាកឲ្យបានគ្រប់គ្រាន់។
- ថ្នាំអាស្ពីរីន(Aspirin ទំ.៣៧៩)ឬថ្នាំអាសេតាមីណូហ្វែន(Acetaminophen ទំ.៣៨០) អាចជួយបន្ថយគ្រុនក្ដៅ និងការឈឺចាប់ខ្លួនប្រាណនិងឈឺក្បាល។ ថ្នាំគ្រុនផ្ដាសាយជាច្រើនដែលមានតម្លៃថ្លៃ ក៏គ្មានប្រសិទ្ធភាពល្អជាង ថ្នាំអាស្ពីរីនទេ។ ដូច្នេះ មិនត្រូវចំណាយលុយដោយឥតប្រយោជន៍ទៅលើវានោះឡើយ។
- គេមិនត្រូវការអាហារពិសេសទេ។ ប៉ុន្តែ ទឹកផ្លែឈើ ជាពិសេសទឹកក្រូចពោធិសាត់ ឬ ទឹកក្រូចឆ្មាអាចជួយបានយ៉ាងប្រសើរ។

សម្រាប់ការព្យាបាលការក្អក និងតឹងច្រមុះដែលបណ្ដាលមកពីផ្ដាសាយ មើលទំព័របន្ទាប់។

*បំរាម ៖* មិនត្រូវឲ្យអង់ទីប៊ីយ៉ូទិកណាមួយ ឬថ្នាំចាក់ផ្សេងៗដល់កុមារដែលកើតជំងឺផ្ដាសាយធម្មតាឡើយ។ វានឹងមិនជួយអ្វីទេ ហើយវាអាចបណ្ដាលឲ្យមានគ្រោះថ្នាក់ទៀតផង។ ជួនកាលរោគសញ្ញាគ្រុនផ្ដាសាយ បណ្ដាលមកពីវីរុសជំងឺគ្រុនស្វិតដៃជើង ហើយការចាក់ថ្នាំឲ្យកុមារអាចនាំឲ្យមានការស្វិតដៃជើងដោយសារជំងឺស្វិតដៃជើងនេះ (មើលទំ. ៣១៤)។

ប្រសិនបើគ្រុនផ្ដាសាយនោះមានរយៈពេលលើសពីមួយអាទិត្យ ឬបើមានគ្រុនក្ដៅ ក្អកមានស្លេសច្រើន (ស្លេសមានខ្ទុះ) ដកដង្ហើមសើៗញាប់ ឬឈឺទ្រូង គេអាចកំពុងកើតជំងឺរលាកទងសួត ឬជំងឺរលាកសួត (ទំ.១៧០និង១៧១)។ ពេលនោះ គេអាចប្រើអង់ទីប៊ីយ៉ូទិកដើម្បីព្យាបាលវា។ គ្រោះថ្នាក់នៃជំងឺគ្រុនផ្ដាសាយធំដែលឈានទៅរកជំងឺរលាកសួតកើតមានភាគច្រើន ចំពោះមនុស្សចាស់ និងចំពោះអ្នកដែលមានជំងឺសួត ដូចជាជំងឺរលាកទងសួតរ៉ាំរ៉ៃ និងចំពោះមនុស្សដែលមិនអាចធ្វើចលនាបានច្រើន។

ជាទូទៅ ការឈឺបំពង់កគឺជាផ្នែកមួយនៃជំងឺគ្រុនផ្ដាសាយ។ វាមិនត្រូវការការព្យាបាលពិសេសទេ ប៉ុន្តែការខ្ពុរមាត់ជាមួយទឹកក្ដៅឧណ្ឌៗឲ្យបានញឹកញាប់ ក៏អាចជួយបានដែរ។ ទោះជាយ៉ាងនេះក៏ដោយ បើការឈឺបំពង់កចាប់ផ្ដើមឡើងភ្លាមៗ ជាមួយនឹងការមានគ្រុនក្ដៅខ្លាំង វាអាចបណ្ដាលមកពីជំងឺរលាកបំពង់ក។ ក្នុងករណីនេះ គេត្រូវការការព្យាបាលពិសេស (ទំ.៣០៩)។

*ការបង្ការជំងឺគ្រុនផ្ដាសាយ ៖*

- ការដេកឲ្យបានគ្រប់គ្រាន់ និងបរិភោគអាហារឲ្យបានត្រឹមត្រូវ នឹងអាចជួយបង្ការជំងឺគ្រុនផ្ដាសាយ។ ការបរិភោគក្រូច ប៉េងប៉ោះ និងផ្លែឈើផ្សេងៗដែលមានជាតិវីតាមីនសេក៏អាចជួយបានដែរ។
- ផ្ទុយពីជំនឿរបស់ប្រជាជនមួយចំនួន ជំងឺគ្រុនផ្ដាសាយមិនមែនបណ្ដាលមកពីភាពត្រជាក់ឬសើមទេ(ទោះបីជាភាពត្រជាក់ សើម ឬការអស់កម្លាំង អាចធ្វើឲ្យជំងឺគ្រុនផ្ដាសាយកាន់តែធ្ងន់ធ្ងរឡើង)។ ជំងឺគ្រុនផ្ដាសាយគឺឆ្លងពីមនុស្សផ្សេងទៀតដែលមានជំងឺនេះ និងការកណ្ដាស់បញ្ចេញមេរោគវីរុសទៅក្នុងខ្យល់។
- ដើម្បីកុំឲ្យជំងឺគ្រុនឆ្លងផ្ដាសាយឆ្លងទៅមនុស្សដទៃទៀត អ្នកជំងឺគួរបរិភោគអាហារនិងដេកដោយឡែកពីគេ ជាពិសេសគួរកុំនៅជិតទារក។ អ្នកជំងឺគួរខ្ទប់ច្រមុះនិងមាត់របស់ខ្លួននៅពេលក្អកឬកណ្ដាស់ម្ដងៗ។
- ដើម្បីបង្ការកុំឲ្យជំងឺគ្រុនផ្ដាសាយប៉ះពាល់ដល់ត្រចៀក (ទំ.៣០៩) **កុំញើសសំបោរ គ្រាន់តែជូតវាបានហើយ។** បង្រៀនកុមារឲ្យធ្វើដូចនេះ។

# ការតឹងច្រមុះ និងហៀរសំបោរ

ការតឹងច្រមុះ ឬហៀរសំបោរអាចបណ្ដាលមកពីជំងឺគ្រុនផ្ដាសាយ ឬអាល់ឡែហ្ស៊ី(មើលទំព័របន្ទាប់)។ ការមានសំបោរជាច្រើននៅក្នុងច្រមុះ អាចបណ្ដាលឲ្យមានការបង្ករោគនៅក្នុងត្រចៀក ចំពោះកុមារ ឬការរលាកនៅក្នុងច្រមុះ ចំពោះមនុស្សចាស់។

*ដើម្បីជួយបំបាត់ការតឹងច្រមុះ ធ្វើដូចខាងក្រោមនេះ ៖*

១. ចំពោះកុមារតូចៗ បូមយកសំបោរចេញដោយប្រដាប់បូមសំបោរ ឬស៊ីរ៉ាំងដែល**គ្មានម្ជុល** ដូចរូបនេះ





២. មនុស្សជំទង់និងមនុស្សចាស់អាចដាក់ទឹកអំបិលបន្តិចនៅក្នុងដៃ ហើយហឺតស្រូបវាឲ្យចូលក្នុងច្រមុះ។ ការធ្វើរបៀបនេះនឹងអាចជួយពង្រាវសំបោរ។ (អំបិលមួយស្លាបព្រាកាហ្វេក្នុងទឹកឆ្អិនកន្លះលីត្រ)

៣. ឆ្អង់ទឹកក្ដៅ ដូចមានពន្យល់នៅទំ.១៨៨ អាចជួយបន្ធូរច្រមុះ។

៤. ជូតសំបោរចេញ តែ**មិនត្រូវញើស**បញ្ចេញឡើយ។ ការញើសសំបោរអាចនាំឲ្យឈឺត្រចៀក និងមានការបង្ករោគនៅក្នុងច្រមុះ។

៥. ចំពោះអ្នកដែលមានឈឺត្រចៀក ឬរលាកច្រមុះជាញឹកញាប់បន្ទាប់ពីមានជំងឺគ្រុនផ្ដាសាយ គេអាចជួយបង្ការបញ្ហាទាំងនេះបានដោយប្រើថ្នាំបន្តក់ច្រមុះបំបាត់ការតឹងច្រមុះ ដូចជា ហ្វេនីលអេហ្វ្រីន(Phenylephrine ទំ.៣៨៥)។ ឬធ្វើថ្នាំបន្តក់ច្រមុះពីថ្នាំគ្រាប់ អេហ្វេទ្រីន(Ephedrine ទំ.៣៨៥)។ បន្ទាប់ពីហឺតស្រូបទឹកអំបិលរួច បន្តក់ទឹកថ្នាំនេះចូលក្នុងច្រមុះដូចរូបនេះ ៖

*ដោយផ្អៀងក្បាលទៅម្ខាងចំហៀង បន្តក់ពីរឬបីដំណក់ក្នុងរន្ធច្រមុះ។ រង់ចាំបន្តិច ហើយបន្ទាប់មក បន្តក់រន្ធច្រមុះម្ខាងទៀត។*



ប្រយ័ត្ន ៖ **កុំប្រើថ្នាំដំណក់បំបាត់ការតឹងច្រមុះឲ្យលើសពីបីដងក្នុងមួយថ្ងៃ និងមិនត្រូវប្រើឲ្យលើសពីបីថ្ងៃទេ។**

ថ្នាំទឹកស៊ីរ៉ូបំបាត់ការតឹងច្រមុះ(ដោយមាន ហ្វេនីលអេហ្វ្រីន(Phenylephrine) ឬថ្នាំដែលស្រដៀងគ្នានេះ) ក៏អាចជួយបានដែរ។

**ការបង្ការការបង្ករោគនៅក្នុងត្រចៀក និងនៅក្នុងច្រមុះ ដោយជូតសំបោរចេញ ប៉ុន្តែកុំញើសសំបោរ។**

# ជំងឺរលាកច្រមុះ

ការរលាកច្រមុះ គឺជាការរលាករន្ធ ឬប្រហោងឆ្អឹងនៅក្នុងច្រមុះ ស្រួចស្រាល់ ឬរ៉ាំរ៉ៃ(មានរយៈពេលយូរ)។ ជាទូទៅវាកើតឡើងបន្ទាប់ពីមនុស្សម្នាក់មានការបង្ករោគនៅក្នុងត្រចៀក ឬបំពង់ក ឬបន្ទាប់ពីមានជំងឺគ្រុនផ្ដាសាយធ្ងន់ធ្ងរ។

*រោគសញ្ញា ៖*



- ឈឺចាប់នៅផ្ទៃកខាងលើ និងខាងក្រោមភ្នែក ដូចក្នុងរូបភាពនេះ (វាធ្វើឲ្យឈឺយ៉ាងខ្លាំងនៅពេលអ្នកគ្រាន់តែគោះថ្នមៗចំពីលើឆ្អឹង ឬនៅពេលគេអោនចុះ)។
- សំបោរខាប់ ឬមានខ្ទុះក្នុងច្រមុះនិងអាចមានក្លិនស្អុយ។ តែងតែមានតឹងច្រមុះ។
- មានគ្រុនក្ដៅ(ជួនកាល)។
- មានការឈឺនៅធ្មេញខ្លះ។

*ការព្យាបាល ៖*

- ផឹកទឹកឲ្យច្រើន។
- ហឺតទឹកអំបិលបន្តិចចូលទៅក្នុងច្រមុះ(ទំ.១៦៤) ឬហឺតយកចំហាយទឹកក្ដៅដើម្បីជួយបន្ធូរច្រមុះ (មើលទំ.១៦៨)។
- ដាក់ស្បៃជ្រលក់ទឹកក្ដៅស្អំលើមុខ។
- ប្រើថ្នាំបន្តក់ច្រមុះបំបាត់ការតឹងច្រមុះ ដូចជា ហ្វេនីលអេហ្វ្រីន(Phenylephrine ណេអូស៊ីណេហ្វ្រីន Neo-synephrine ទំ.៣៨៤)។
- ប្រើអង់ទីប៊ីយ៉ូទិកដូចជា តេត្រាស៊ីគ្លីន(ទំ.៣៥៦) អំពីស៊ីលីន(ទំ.៣៥៣) ឬប៉េនីស៊ីលីន(ទំ.៣៥១)។
- បើគ្មានការធូរស្រាលទេ រកជំនួយពីគ្រូពេទ្យ។

*ការបង្ការ ៖*

បើអ្នកកើតជំងឺគ្រុនផ្ដាសាយ ឬមានតឹងច្រមុះ ព្យាយាមបន្ធូរច្រមុះ ដោយធ្វើតាមការពន្យល់នៅទំព័រ១៦៤។

# ការរលាកច្រមុះដោយសារការអាល់ឡែហ្ស៊ី



ការហៀរសំបោរ និងរមាស់ភ្នែកអាចបណ្ដាលមកពីការមាន ប្រតិកម្មអាល់ឡែហ្ស៊ី ជាមួយអ្វីម៉្យាងនៅក្នុងខ្យល់ ដែលមនុស្សយើងបានដកដង្ហើម ស្រូបចូល(អានទំព័របន្ទាប់)។ បញ្ហានេះតែងតែមានសភាពធ្ងន់ធ្ងរទៅតាមរដូវកាលណាមួយនៃឆ្នាំ។

*ការព្យាបាល ៖*

ប្រើថ្នាំអង់ទីអ៊ីស្តាមីន(antihistamine) ដូចជាខ្លរ័ហ្វេនីរ៉ាមីន (Chlorpheniramine ទំ.៣៨៧)។ ឌីមែននីឌ្រីណាត(Dimenhydrinate ដ្រាម៉ាមីន Dramamine ទំ.៣៨៧) **ដែលតែងតែត្រូវបានគេលក់សម្រាប់ បំបាត់ការពុលឡាន ក៏មានប្រសិទ្ធភាពដែរ។**

*ការបង្ការ ៖*

រកឲ្យឃើញវត្ថុដែលបណ្ដាលឲ្យមានប្រតិកម្មអាល់ឡែហ្ស៊ីនេះ។ ឧទាហរណ៍ ៖ ធូលីដី រោមមាន់ **លំអងផ្កា** ផ្សិត) ហើយខំជៀសឲ្យឆ្ងាយពីរបស់ទាំងនេះ។

# ប្រតិកម្មអាល់ឡែហ្ស៊ី

អាល់ឡែហ្ស៊ីគឺជាការរំខាន ឬជាប្រតិកម្មមួយ ដែលកើតតែលើមនុស្សដែលងាយឆ្លើយតប ឬងាយអាល់ឡែហ្ស៊ីជាមួយនឹងវត្ថុផ្សេងៗ នៅពេលដែលវត្ថុនោះត្រូវបាន ៖

- ដកដង្ហើមចូល
- បរិភោគ
- ចាក់បញ្ចូលទៅក្នុងខ្លួន
- ឬប៉ះជាមួយស្បែក។

ប្រតិកម្មអាល់ឡែហ្ស៊ី ដែលអាចមានកម្រិតស្រាល ឬកម្រិតធ្ងន់ធ្ងរ រួមមាន ៖

- មានកន្ទួលរមាស់ មានពកដុំៗ ឬ មានកន្ទាលត្រអាក (ទំ.២០៣)។
- ហៀរសំបោរ រមាស់ និងផ្សាភ្នែក(ទំ.១៦៥)។
- ក្រហាយបំពង់ក ពិបាកដកដង្ហើម ឬមានហឺត (អានទំព័របន្ទាប់)។
- ស្ពឹក (ទំ.៧០)
- រាក (ចំពោះកុមារដែលមានអាល់ឡែហ្ស៊ីជាមួយទឹកដោះគោ ជាមូលហេតុកម្រនៃការរាក ទំ.១៥៦)។

អាល់ឡែហ្ស៊ីមិនមែនជាជំងឺទេ ហើយក៏មិនអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានដែរ។ ប៉ុន្តែកុមារដែលមានឪពុកម្តាយមានអាល់ឡែហ្ស៊ី ក៏ទំនងជានឹងមានអាល់ឡែហ្ស៊ីដែរ។

ជាទូទៅ អ្នកដែលមានអាល់ឡែហ្ស៊ីតែងតែមានបញ្ហានេះទៅតាមរដូវកាលណាមួយ ឬនៅពេលដែលពួកគេបានប៉ះពាល់នឹងសារធាតុដែលអាចរំខានដល់ពួកគេ។ មូលហេតុញឹកញាប់នៃប្រតិកម្មអាល់ឡែហ្ស៊ី គឺ ៖




ថ្នាំមួយចំនួន ជាពិសេស ការចាក់ថ្នាំប៉េនីស៊ីលីន ឬស៊ីរ៉ូមសេះ (ទំ.៧០)

រោមឆ្មានិងរោមសត្វឯទៀត

អាហារពិសេសមួយចំនួន ដូចជា ត្រី បង្កងសមុទ្រ ក្តាម លៀស ខ្យង ស្រាបៀរៗល។

# ជំងឺហឺត




អ្នកជំងឺហឺតអាចមានការប្រកាច់ និងមានការពិបាកដកដង្ហើម។ ស្តាប់រកសំឡេងដង្ហើមឆ្មា សំឡេងងឺតៗហើយវែង ជាពិសេសនៅពេលដកដង្ហើមចេញ។ នៅពេលដែលគេដកដង្ហើមចូល ស្បែកដែលនៅខាងលើឆ្អឹងដងកាំបិត និងចន្លោះឆ្អឹងជំនីរបស់គេអាចផតចូល ដោយសារគេប្រឹងស្រូបយកខ្យល់។ បើគេមិនអាចស្រូបខ្យល់ឲ្យបានគ្រប់គ្រាន់ទេ នោះក្រចកនិងបបូរមាត់របស់គេនឹងឡើងខៀវ ហើយសរសៃឈាមវ៉ែននៅករបស់គេអាចប៉ោង។ ធម្មតា គ្មានគ្រុនក្តៅទេ។

ជាទូទៅ ជំងឺហឺតចាប់ផ្តើមកើតក្នុងវ័យកុមារភាព ហើយអាចជាបញ្ហាអស់មួយជីវិត។ វាមិនមែនជា***ជំងឺឆ្លង***ទេ ប៉ុន្តែវាច្រើនកើតលើកុមារដែលមានសាច់ញាតិមានជំងឺហឺតនេះ។ ជាទូទៅ វាកាន់តែធ្ងន់ធ្ងរក្នុងខែខ្លះ ក្នុងមួយឆ្នាំៗ ឬនៅពេលយប់។ មនុស្សដែលមានជំងឺហឺតជាយូរឆ្នាំ អាចកើតមានការស្ទះខ្យល់ក្នុងសួត(emphysema) (មើលទំ.១៧០)។

ការធ្វើទុក្ខនៃជំងឺហឺត អាចបង្កឡើងដោយការបរិភោគអាហារប្រភេទខ្លះ ឬការដកដង្ហើមចូលនូវវត្ថុ ដែលមនុស្សនោះមានអាល់ឡែហ្ស៊ីជាមួយ(មើលទំ.១៦៦)។ ចំពោះកុមារតូចៗ ជំងឺហឺតចាប់ផ្តើមធ្វើទុក្ខដោយសារមានជំងឺគ្រុនផ្តាសាយ។ ចំពោះមនុស្សខ្លះ ជំងឺហឺតធ្វើទុក្ខនៅពេលមានអារម្មណ៍ភ័យខ្លាច ឬការព្រួយបារម្ភខ្លាំង។ ជំងឺហឺតក៏អាចបណ្តាលមកពីខ្យល់អាកាសមិនស្អាត(ផ្សែងពុល) ដូចជាផ្សែងបារី ផ្សែងដុតសំរាម ឬផ្សែងពីចង្ក្រាន និងផ្សែងពីការដុតនៅតាមវាលស្រែ ឬផ្សែងឡាន និងផ្សែងតាមរោងចក្រឧស្សាហកម្មផ្សេងៗ។

*ការព្យាបាល ៖*

- បើជំងឺហឺតមានសភាពកាន់តែធ្ងន់ធ្ងរនៅពេលស្នាក់នៅក្នុងផ្ទះ គេគួរចេញទៅខាងក្រៅផ្ទះ ទៅកន្លែងដែលមានខ្យល់អាកាសល្អបំផុត។ រក្សាការស្ងៀមស្ងាត់ សុភាពជាមួយអ្នកជំងឺហឺត។ ត្រូវជួយពួកគេ។
- ផ្តល់ទឹកឲ្យបានច្រើន។ ការធ្វើរបៀបនេះជួយពង្រាវស្លេស និងធ្វើឲ្យងាយដកដង្ហើម។ ការហឺតចំហាយទឹកក្តៅក៏អាចជួយឲ្យបានធូរស្រាលខ្លះដែរ(មើលទំ.១៦៨)។
- ចំពោះពេលធ្វើទុក្ខ ព្យាបាលដោយប្រើប្រដាប់ហឺតថ្នាំសាល់ប៊ុយតាម៉ុល(Salbutamol មើលទំ.៣៨៥) ឲ្យបានញឹកញាប់តាមត្រូវការ។ ថ្នាំនេះគឺជាថ្នាំបាញ់ដែលអ្នកត្រូវហឺតចូលយ៉ាងវែងតាមដែលអាចធ្វើបាន។



មើលទំ.៣៨៩ដើម្បីរៀនពីវិធីធ្វើបំពង់ សម្រាប់ប្រដាប់ហឺតរបស់អ្នក

- ចំពោះការធ្វើទុក្ខញឹកញាប់ ឬជំងឺហឺតដែលធ្វើឲ្យអ្នកដង្ហក់រកដង្ហើមពេលដើរឬពេលហាត់ប្រាណតិចតួច ប្រើប្រដាប់ហឺតថ្នាំ (beclomethasone មើលទំ.៣៨៥)។ ការប្រើប្រដាប់ហឺតថ្នាំនេះ អាចបង្ការការធ្វើទុក្ខ សន្សំសំចៃប្រាក់ និងធ្វើឲ្យអ្នកមានការធូរស្រាល ជាងការឆ្លើយតបរបស់ការសង្គ្រោះបន្ទាន់ផ្នែកជំងឺហឺត។ ការប្រើបំពង់មួយជាមួយនឹងប្រដាប់ហឺតរបស់អ្នក ធ្វើឲ្យថ្នាំចូលទៅក្នុងសួតរបស់អ្នកបានកាន់តែច្រើន។
- ក្នុងពេលបន្ទាន់ ដែលអ្នកគ្មានថ្នាំសាល់ប៊ុយតាម៉ុល អ្នកអាចចាក់ថ្នាំអេពីណេហ្វ្រីន(អាដ្រេណាលីនAdrenalin មើលទំ.៣៨៦) នៅក្រោមស្បែក។
- ប្រសិនបើអ្នកនោះមានគ្រុនក្តៅទៀត ឬប្រសិនបើហឺតធ្វើទុក្ខលើសពី៣ថ្ងៃ ឲ្យថ្នាំអាម៉ុកស៊ីស៊ីលីន(ទំ.៣៥៤) ឬថ្នាំអេរីត្រូមីស៊ីន(Erythromycin ទំ.៣៥៥)។
- ក្នុងករណីកម្រ ព្រូនអាចបណ្តាលឲ្យកើតហឺតបានដែរ។ សាកល្បងឲ្យថ្នាំមេបង់ដាហ្សូល(ទំ.៣៧៤) ទៅកុមារដែលចាប់ផ្តើមមានជំងឺហឺត បើអ្នកគិតថាគេមានព្រូន។
- **បើអ្នកជំងឺនៅតែមិនធូរស្រាលទេ សូមស្វែងរកជំនួយពីគ្រូពេទ្យ។**

*ការបង្ការ ៖*

មនុស្សដែលមានជំងឺហឺតគួរតែជៀសវាងការបរិភោគអាហារ ឬការដកដង្ហើមចូលនូវវត្ថុណាដែលបណ្តាលឲ្យជំងឺហឺតធ្វើទុក្ខ។ ផ្ទះ ឬកន្លែងធ្វើការត្រូវរក្សាឲ្យបានស្អាតជានិច្ច។ កុំឲ្យមានមាន់ ឬសត្វដទៃទៀតចូលក្នុងផ្ទះ។ ដាក់កំរាលពូកហាលថ្ងៃ។ ជួនកាល ការដេកនៅខាងក្រៅផ្ទះ នៅកណ្តាលវាល ក៏អាចជួយដែរ។ ផឹកទឹកយ៉ាងតិច៨កែវ ក្នុងមួយថ្ងៃ ដើម្បីឲ្យស្លេសរាវ។ អ្នកជំងឺហឺតអាចបានធូរស្រាល បើគេស្ថិតនៅកន្លែងដែលមានខ្យល់អាកាសល្អ។

**បើអ្នកមានជំងឺហឺត កុំជក់បារី ព្រោះការជក់បារីធ្វើឲ្យសួតអ្នកខូចកាន់តែខ្លាំង។**

# ការក្អក

ក្អកមិនមែនជាជំងឺទេ ប៉ុន្តែវាជាសញ្ញានៃជំងឺផ្សេងៗដែលទាក់ទងនឹងបំពង់ក សួត ឬទងសួត (បំពង់ខ្យល់សម្រាប់នាំខ្យល់ចូលក្នុងសួត)។ ខាងក្រោមគឺជាបញ្ហាមួយចំនួនដែលបណ្តាលឲ្យក្អក ៖

| ក្អកស្ងួតមានស្លេសបន្តិចបន្តួច ឬគ្មានស្លេស | ក្អកមានស្លេសបន្តិចបន្តួច ឬច្រើន | ក្អកមានសំឡេងង៉ឺតៗ ឬសំឡេងដូចក្អកមាន់ហើយពិបាកដកដង្ហើម |
|---|---|---|
| . គ្រុនផ្តាសាយ (ទំ.១៦៣) | . រលាកទងសួត (ទំ.១៧០) | . ជំងឺហឺត (ទំ.១៦៧) |
| . ព្រូនពេលដែលវាចូលទៅក្នុងសួត (ទំ.១៤០) | . រលាកសួត (ទំ.១៧១) | . ក្អកមាន់ (ទំ.៣១៣) |
| . កញ្ជ្រឹល (ទំ.៣១១) | . ជំងឺហឺត (ទំ.១៦៧) | . ខាន់ស្លាក់ (ទំ.៣១៣) |
| . ក្អកជក់បារី (ទំ.១៤៩) | . ក្អកជក់បារី ជាពិសេសនៅពេលក្រោកពីដំណេកនៅពេលព្រលឹម (ទំ.១៤៩) | . ជំងឺបេះដូង (ទំ.៣២៥) |
| | | . មានអ្វីជាប់ក្នុងបំពង់ក (ទំ.៧៩) |

| ក្អករ៉ាំរ៉ៃ ឬក្អកមិនឈប់ | ក្អកមានឈាម |
|---|---|
| . របេង (ទំ.១៧៩) | . របេង (ទំ.១៧៩) |
| . ក្អករបៀបអ្នកជក់បារីឬរបៀបអ្នកជីកអណ្តូងរ៉ែ (ទំ.១៤៩) | . រលាកសួត (ស្លេសមានពណ៌លឿង បៃតង ឬស្លេសមានឈាមអន្លាយ ទំ.១៧១) |
| . ហឺត (ធ្វើទុក្ខម្តងហើយម្តងទៀតទំ.១៦៧) | . មានព្រូនច្រើន (ទំ.១៤០) |
| . រលាកទងសួតរ៉ាំរ៉ៃ (ទំ.១៧០) | . មហារីកសួត ឬមហារីកបំពង់ក (ទំ.១៤៩) |
| . ការស្ទះខ្យល់ក្នុងសួត (ទំ.១៧០) | |

ក្អកគឺជាវិធីមួយរបស់រាងកាយក្នុងការសំអាតផ្លូវដង្ហើមនិងបញ្ចេញស្លេស(សំបោរដែលមានខ្ទុះ)និងមេរោគពីក្នុងបំពង់កនិងសួត។ ដូច្នេះនៅពេលដែលក្អកមានស្លេស **កុំប្រើថ្នាំដើម្បីបំបាត់ក្អក ប៉ុន្តែគប្បីធ្វើយ៉ាងណាដើម្បីជួយឲ្យស្លេសរាវ និងបញ្ចេញវាមកក្រៅ។**

*ការព្យាបាលក្អក ៖*



១. **ដើម្បីធ្វើឲ្យស្លេសរាវ** និងបន្ធូរការក្អក **ផឹកទឹកឲ្យបានច្រើន**។ មធ្យោបាយបែបនេះប្រសើរជាងការប្រើថ្នាំ។

ជាមួយគ្នានេះដែរ **ហឺតចំហាយទឹកក្តៅផងដែរ**។ អង្គុយលើកៅអីដែលមានធុងទឹកក្តៅក្បែរជើង ហើយគ្របភួយពីលើក្បាល និងធុងទឹកក្តៅដើម្បីស្រូបយកចំហាយចូល រយៈពេល១៥នាទី។ ធ្វើដូច្នេះជាច្រើនដងក្នុងមួយថ្ងៃ។ មនុស្សខ្លះចូលចិត្ត ស្លឹកជីរឬជាតិប្រេងខ្យល់ ប៉ុន្តែទឹកក្តៅទទេក៏អាចមានប្រសិទ្ធភាពដែរ។

ការប្រុងប្រយត្ន័ ៖ មិនត្រូវប្រើប្រេងខ្យល់ឬស្លឹកជីរ ប្រសិនបើអ្នកនោះកើតជំងឺហឺត ព្រោះវាអាចធ្វើឲ្យជំងឺកាន់តែធ្ងន់ធ្ងរ។

២. **ចំពោះការក្អកគ្រប់ប្រភេទ** ជាពិសេសក្អកស្ងួត អ្នកអាចប្រើថ្នាំក្អកស៊ីរ៉ូដូចខាងក្រោមនេះ ៖




ផឹកមួយស្លាបព្រាកាហ្វេរៀងរាល់ ពីរឬបីម៉ោងម្តង។

*ប្រយ័ត្ន ៖* មិនត្រូវឲ្យទឹកឃ្មុំទៅទារកដែលមានអាយុក្រោមមួយឆ្នាំ។ ជាការល្អ ធ្វើស៊ីរ៉ូជាមួយនឹងស្ករជំនួសទឹកឃ្មុំវិញ។

៣. **ចំពោះការក្អកស្ងួតធ្ងន់ធ្ងរ ដែលធ្វើឲ្យអ្នកមិនអាចដេកបាន** អ្នកអាចផឹកថ្នាំទឹកស៊ីរ៉ូមានជាតិកូដេអ៊ីន (codeine ទំ.៣៨៤) ។ ថ្នាំគ្រាប់អាស្ពីរីនមានជាតិកូដេអ៊ីន (ឬអាស្ពីរីនទទេក៏បាន)ក៏អាចជួយបានដែរ។ បើមានស្លេសច្រើន ឬមានសំឡេងងីតៗ កុំប្រើថ្នាំកូដេអ៊ីន។

៤. **ចំពោះការក្អកមានសំឡេងងីតៗ** (ពិបាកដកដង្ហើម និងដកដង្ហើមឮសូរ) អានអំពីជំងឺហឺត (ទំ.១៦៧) ជំងឺរលាកទងសួតរ៉ាំរ៉ៃ (ទំ.១៧០) និងជំងឺបេះដូង (ទំ.៣២៥)។

៥. **ព្យាយាមស្វែងយល់អំពីជំងឺដែលបណ្តាលឲ្យក្អក ហើយព្យាបាលវា**។ បើក្អកយូរថ្ងៃហើយមានឈាម ខ្ទុះ ឬកំហាកមានក្លិនស្អុយ ឬបើអ្នកជំងឺស្រកទម្ងន់ ហើយនៅតែពិបាកដកដង្ហើម សូមទៅជួបគ្រូពេទ្យ។

៦. **បើមានជំងឺក្អកប្រភេទណាមួយ កុំជក់បារី។** ការជក់បារីនាំឲ្យខូចសួត។

**ដើម្បីបង្ការក្អក កុំជក់បារី ។**

**ដើម្បីព្យាបាលក្អក ព្យាបាលជំងឺដែលបណ្តាលឲ្យក្អក ហើយកុំជក់បារី ។**

**ដើម្បីសម្រាលការក្អកនិងធ្វើឲ្យស្លេសរាវ ផឹកទឹកឲ្យច្រើន និងកុំជក់បារី ។**

របៀបធ្វើឲ្យស្លេសចេញពីសួត ៖

ពេលដែលអ្នកជំងឺក្អកខ្លាំង ហើយជាមនុស្សចាស់ ឬក៏ខ្សោយ ហើយមិនអាចបញ្ចេញស្លេសខាប់ស្អិតពីក្នុងទ្រូងបាន ការផឹកទឹកឲ្យបានច្រើននឹងអាចជួយបាន។ ប៉ុន្តែក៏ត្រូវអនុវត្តដូចខាងក្រោមនេះដែរ។



- ដំបូង ឲ្យស្រូបចំហាយទឹកក្តៅដើម្បីឲ្យស្លេសរាវ។
- គោះខ្នងគាត់ស្រាលៗ ដោយក្បង់ដៃ។ ការធ្វើដូចនេះនឹងអាចឲ្យស្លេសចេញមកក្រៅបាន។

# ជំងឺរលាកទងសួត

ជំងឺរលាកទងសួតគឺជាការបង្ករោគនៅទងសួត ឬបំពង់ដែលនាំខ្យល់ចូលក្នុងសួត។ វាធ្វើឲ្យក្អកឮខ្លាំងៗ ហើយច្រើនមានស្លេស។ ជំងឺរលាកទងសួតតែងបណ្តាលមកពីវីរុស ដូច្នេះថ្នាំអង់ទីប៊ីយ៉ូទិកមិនអាចជួយបានទេ។ **ប្រើថ្នាំអង់ទីប៊ីយ៉ូទិក តែចំពោះជំងឺរលាកទងសួតដែលមានរយៈពេលលើសពីមួយអាទិត្យ** ហើយមិនធូរស្រាល បើអ្នកជំងឺបង្ហាញសញ្ញានៃជំងឺ**រលាកសួត** (មើលទំព័របន្ទាប់) ឬបើគាត់មាន**ជំងឺសួតរ៉ាំរ៉ៃ**។

## ជំងឺរលាកទងសួតរ៉ាំរ៉ៃ



*ការស្ទះខ្យល់ក្នុងសួត បណ្តាលមកពីជំងឺហឺតរ៉ាំរ៉ៃ រលាកទងសួតរ៉ាំរ៉ៃ ឬការជក់បារី*

*រោគសញ្ញា ៖*

- ក្អកមានស្លេស រយៈពេលជាច្រើនខែ ឬច្រើនឆ្នាំ។ ជួនកាល ការក្អកមានសភាពកាន់តែធ្ងន់ធ្ងរ  ហើយអាចមានគ្រុនក្តៅទៀតផង។ អ្នកដែលមានក្អករបៀបនេះ ប៉ុន្តែពុំមានជំងឺរ៉ាំរ៉ៃផ្សេងទៀត ដូចជា ជំងឺរបេង ឬជំងឺហឺត នោះគាត់ប្រហែលជាមានជំងឺរលាកទងសួតរ៉ាំរ៉ៃ។
- វាច្រើនកើតលើមនុស្សវ័យចំណាស់ដែលបានជក់បារីច្រើន។
- វាអាចបណ្តាលឲ្យមានជំងឺស្ទះខ្យល់ក្នុងសួត (emphysema)ដែលជាជំងឺធ្ងន់ធ្ងរ និងមិនអាចព្យាបាលជា ដែលក្នុងជំងឺនេះ កូនថង់សួតនៅក្នុងសួតត្រូវបានធ្លុះធ្លាយ។ អ្នកមានជំងឺស្ទះខ្យល់ក្នុងសួត ក្នុងពេលដកដង្ហើមម្តងៗ មានការពិបាកយ៉ាងខ្លាំង ជាពិសេសពេលហាត់ប្រាណ ហើយដើមទ្រូងរបស់គាត់ឡើងប៉ោងដូចពាង។

*ការព្យាបាល ៖*

- ♦ ឈប់ជក់បារី
- ♦ ប្រើថ្នាំប្រឆាំងជំងឺហឺត ដែលមាន អេហ្វេទ្រីន(Ephedrine) ឬតេអូហ្វីលីន(Theophylline ទំ.៣៨៥)
- ♦ អ្នកជំងឺរលាកសួតរ៉ាំរ៉ៃគួរប្រើថ្នាំ អំពីស៊ីលីន ឬតេត្រាស៊ីគ្លីន រាល់ពេលមានគ្រុនផ្តាសាយ ដែលមានគ្រុនក្តៅ។
- ♦ បើអ្នកជំងឺមានការពិបាកក្អកបញ្ចេញស្លេសខាប់ៗ ហឺតចំហាយទឹកក្តៅ (ទំ.១៦៨) រួចយកដៃទះខ្នងឲ្យធ្លាក់ស្លេស (ទំ.១៦៩)។



**បើអ្នកមានក្អករ៉ាំរ៉ៃ ឬចង់បង្ការការក្អក**

**កុំជក់បារី!!!!**



# ជំងឺរលាកសួត

ជំងឺរលាកសួតគឺជាការបង្ករោគ**ស្រួចស្រាល់**ម្យ៉ាងនៃសួត។ វាច្រើនកើតមានបន្ទាប់ពីមានជំងឺផ្សេងៗទៀតនៃផ្លូវដង្ហើម ដូចជា កញ្ជ្រឹល ក្អកមាន់ ផ្តាសាយ រលាកទងសួត ហឺត ឬជំងឺធ្ងន់ធ្ងរដទៃទៀត ជាពិសេសចំពោះទារក និងមនុស្សចាស់។ ដូចគ្នានេះដែរ អ្នកកើតជំងឺអេដស៍ក៏អាចបណ្តាលឲ្យកើតជំងឺរលាកសួតដែរ។

*រោគសញ្ញា ៖*




- ញាក់ភ្លាមៗ និងមានគ្រុនក្តៅខ្លាំង ។
- ដកដង្ហើមញាប់ ហើយជ្រៅៗ ជួនកាលឮសំឡេងថ្ងូរ ឬ សំឡេងតឿៗផឹតៗ។ រន្ធច្រមុះអាចរីកប៉ោងពេលដកដង្ហើមម្តងៗ។
- គ្រុនក្តៅ(ជួនកាលទារក ឬមនុស្សចាស់ ឬមនុស្សដែលខ្សោយខ្លាំង ដែលមានជំងឺរលាកសួតធ្ងន់ធ្ងរ អាចមានគ្រុនក្តៅបន្តិចបន្តួច ឬគ្មាន)។
- ក្អក(ច្រើនមានស្លេសពណ៌លឿង ពណ៌បៃតង ពណ៌ក្រហម ឬមានឈាមលាយរំអឹលបន្តិចៗ)។
- ពេលខ្លះឈឺទ្រូង។
- អ្នកជំងឺមានសភាពធ្ងន់ធ្ងរ។
- មានជំពៅនៅលើមុខឬបបូរមាត់ (ទំ.២៣២)។

កុមារដែលមានជំងឺធ្ងន់ធ្ងរ ដែលដកដង្ហើមលើសពី**៥០ដង**ក្នុងមួយនាទីអាចមានជំងឺរលាកសួត។

(បើមានការដកដង្ហើមញាប់ហើយជ្រៅៗ សូមពិនិត្យមើលការខ្សោះជាតិទឹក(ទំ.១៥១)។

*ការព្យាបាល*

- ចំពោះជំងឺរលាកសួត ការព្យាបាលដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិក អាចធ្វើឲ្យជៀសផុតពីការស្លាប់បាន។ ឲ្យថ្នាំប៉េនីស៊ីលីន (penicillin)(ទំ.៣៥១) ថ្នាំកូទ្រីមម៉ុកសាសូល(Cotrimoxazole ទំ.៣៥៨) ឬថ្នាំអេរីត្រូមីស៊ីន (Erythromycin ទំ.៣៥៥)។ ចំពោះករណីធ្ងន់ធ្ងរ ចាក់ប្រូកាអ៊ីនប៉េនីស៊ីលីន(Procaine Penicillin ទំ.៣៥៣) មនុស្សធំ ៖ ៤០០,០០០ឯកតា(២៥០ម.ក្រ) ២ឬ៣ដងក្នុងមួយថ្ងៃ ឬឲ្យថ្នាំអាម៉ុកស៊ីស៊ីលីនតាមមាត់(ទំ.៣៥៣ ទៅ៣៥៤) ៥០០ម.ក្រ ៣ដងក្នុងមួយថ្ងៃ។ ឲ្យកុមារតូចៗ ១/៤ ឬ ១/២នៃកម្រិតប្រើរបស់មនុស្សធំ។ សម្រាប់កុមារអាយុក្រោម៦ឆ្នាំ ល្អបំផុតត្រូវប្រើថ្នាំអាម៉ុកស៊ីស៊ីលីន។
- ឲ្យអាស្ពីរីន(ទំ.៣៧៩)ឬអាសេតាមីណូហ្វេន(ទំ.៣៨០)ដើម្បីបញ្ចុះកម្តៅ និងបន្ថយការឈឺចាប់ ។
- ផ្តល់ទឹកឲ្យបានច្រើន បើអ្នកជំងឺបរិភោគមិនបាន ឲ្យបរិភោគអាហាររាវ ឬទឹកអ៊្វាលីត (ទំ.១៥២)។
- សម្រាលការក្អក ឬធ្វើឲ្យស្លេសរាវ តាមរយៈការឲ្យអ្នកជំងឺផឹកទឹកឲ្យបានច្រើន ហើយឲ្យគាត់ឆ្អុងទឹកក្តៅ (ទំ.១៦៨) ។ វិធីបញ្ចេញស្លេសក៏អាចជួយដែរ (ទំ.១៦៩)។
- បើគេដកដង្ហើមមានសំឡេងតឿៗ ការប្រើថ្នាំប្រឆាំងជំងឺហឺត ដែលមានថ្នាំតេអូហ្វេលីន(Theophylline) ឬ អេហ្វេទ្រីន(Ephedrine) ក៏អាចជួយឲ្យធូរស្បើយបានដែរ។

# ជំងឺរលាកថ្លើម

ជំងឺរលាកថ្លើម គឺជាឈ្មោះការបង្ករោគជាច្រើនដោយវីរុស (ដូចជា ជំងឺរលាកថ្លើមប្រភេទអា ប្រភេទបេ ប្រភេទសេ) ដែលធ្វើឲ្យខូចថ្លើម។ ទោះបីជានៅតាមតំបន់ខ្លះគេហៅវាថាជាជំងឺគ្រុនក្តៅក៏ដោយ (ទំ.២៦) ជាញឹកញាប់ជំងឺរលាកថ្លើម បណ្តាលឲ្យមានគ្រុនក្តៅបន្តិចបន្តួច ឬគ្មាន។

អ្នកដែលមានជំងឺរលាកជំងឺថ្លើមប្រភេទអា ឬប្រភេទបេ តែងតែមានសភាពធ្ងន់ធ្ងរក្នុងរយៈពេល២ទៅ៣អាទិត្យ ហើយក្រោយមកចេះតែខ្សោយទៅៗពី ១ខែទៅ៤ខែ បន្ទាប់មកក៏ចាប់ផ្តើមធូរស្រាលវិញ។ ជំងឺរលាកថ្លើមអាចឆ្លងយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត បើទោះជារោគសញ្ញានៃជំងឺនេះបានបាត់ទៅវិញក៏ដោយ។

ជំងឺរលាកថ្លើមប្រភេទអា ច្រើនតែមានសភាពស្រាលចំពោះកុមារ និងធ្ងន់ធ្ងរចំពោះមនុស្សចាស់ និងស្ត្រីមានផ្ទៃពោះ។ ជំងឺរលាកថ្លើមប្រភេទបេ មានសភាពធ្ងន់ធ្ងរជាង ហើយអាចបណ្តាលឲ្យមានសម្លាកនៅថ្លើមរហូត(ក្រិនថ្លើម) មហារីកថ្លើម និងស្លាប់។ ជំងឺរលាកថ្លើមប្រភេទសេ ក៏មានគ្រោះថ្នាក់ណាស់ដែរ ហើយវាអាចធ្វើឲ្យមានការបង្ករោគជាអចិន្ត្រៃយ៍នៅថ្លើម។ ជំងឺរលាកថ្លើមប្រភេទសេ ជាមូលហេតុចំបងនៃការស្លាប់ ចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។

*រោគសញ្ញា ៖*

- *មានអារម្មណ៍អស់កម្លាំង។ មិនចង់បរិភោគ ឬជក់បារី។ ជួនកាល មិនបរិភោគជាច្រើនថ្ងៃ។*
- *ជួនកាលមានការឈឺចាប់នៅផ្នែកខាងស្តាំជិតថ្លើម ហើយជួនកាលមានការឈឺចាប់តាមសន្លាក់និងសាច់ដុំ។*



- *អាចមានគ្រុនក្តៅ*
- *ពីរបីថ្ងៃក្រោយ ភ្នែកចាប់ផ្តើមឡើងលឿង។*
- *ការឃើញឬធុំក្លិនអាហារអាចធ្វើឲ្យចង់ក្អួត*
- *ទឹកនោមមានពណ៌ចាស់ដូចជា ទឹកកូកាកូឡា ហើយលាមកប្រែជា ពណ៌ស ឬអាចមានរាក។*

*ការព្យាបាល ៖*

- ថ្នាំអង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាពប្រឆាំងជំងឺរលាកថ្លើមទេ។ តាមពិត ថ្នាំខ្លះអាចធ្វើឲ្យថ្លើមដែលកំពុងមានជំងឺមានការខូចខាតកាន់តែខ្លាំងឡើង។ **កុំប្រើថ្នាំ**។
- អ្នកជំងឺគួរសម្រាកហើយផឹកទឹកឲ្យបានច្រើន។ បើគេមិនព្រមបរិភោគអាហារ ឲ្យផឹកទឹកក្រូច ផ្លែល្ហុង និងផ្លែឈើដទៃទៀត បន្ថែមលើទឹកស៊ុបសាច់និងអាហារផ្សេងៗដែលមានជាតិប្រូតេអ៊ីន។ ការប្រើថ្នាំវីតាមីន ក៏អាចជួយដែរ។ ដើម្បីបំបាត់ការក្អួត មើលទំ.១៦១។
- នៅពេលដែលអ្នកជំងឺអាចបរិភោគបាន ផ្តល់អាហារចំរុះ។ បន្លែនិងផ្លែឈើគឺជាអាហារល្អ ហើយមានជាតិប្រូតេអ៊ីនខ្លះ(ទំ.១១០ទៅ១១១)។ ប៉ុន្តែ មិនត្រូវឲ្យប្រូតេអ៊ីនច្រើនពេកទេ (សាច់ ស៊ុត ត្រី ជាដើម) ព្រោះវាធ្វើឲ្យថ្លើមដែលមានជំងឺពិបាកធ្វើការ។ ជៀសវាងអាហារដែលមានជាតិខ្លាញ់។ **មិនត្រូវផឹកភេសជ្ជៈជាតិអាល់កុល គ្រឿងស្រវឹង**ផ្សេងៗ យ៉ាងតិចរយៈពេល៦ខែ។

*ការបង្ការ ៖*

- ជាញឹកញាប់កុមារតូចៗដែលមានជំងឺរលាកថ្លើមមិនមានចេញរោគសញ្ញានៃជំងឺទេ ប៉ុន្តែវាអាចឆ្លងជំងឺនេះទៅអ្នកដទៃទៀតបាន។ វាជាការសំខាន់ណាស់ដែលមនុស្សគ្រប់គ្នាក្នុងគ្រួសារធ្វើតាមការណែនាំនៃក្បួនអនាម័យដោយប្រុងប្រយត្ន័បំផុត(មើលទំ.១៣៣ទៅ១៣៩)។
- វីរុសជំងឺរលាកថ្លើមប្រភេទអា ឆ្លងពីលាមករបស់មនុស្សម្នាក់ទៅដល់មាត់របស់មនុស្សម្នាក់ទៀត តាមរយៈទឹក ឬអាហារកខ្វក់។ ដើម្បីការពារអ្នកដទៃកុំឲ្យឆ្លងជំងឺនេះ កប់លាមកអ្នកដែលមានជំងឺនោះ។ អ្នកជំងឺ គ្រួសាររបស់អ្នកជំងឺ និងអ្នកថែទាំ ត្រូវតែមានអនាម័យជានិច្ចដោយលាងដៃឲ្យបានញឹកញាប់។
- វីរុសជំងឺរលាកថ្លើមប្រភេទបេ និងប្រភេទសេ អាចឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមរយៈការរួមភេទ ការចាក់ថ្នាំដោយប្រើម្ជុលមិនស្អាត ការចាក់បញ្ចូលឈាមដែលមានមេរោគ និងការឆ្លងពីម្តាយទៅទារកក្នុងពេលសម្រាល។ ជំហាននៃការបង្ការការឆ្លងជំងឺរលាកថ្លើមទៅអ្នកដទៃគឺ ៖ ប្រើស្រោមអនាម័យនៅពេលរួមភេទ(ទំ.២៩០) ធ្វើតាមការណែនាំអំពីវិធីបង្ការជំងឺអេដស៍ ទំ.៤០១ ហើយត្រូវតែស្ងោរស៊ីរ៉ាំងនិងម្ជុលជានិច្ចមុនពេលប្រើ (ទំ.៧៤)។
- នាពេលបច្ចុប្បន្នគេមានថ្នាំចាក់បង្ការជំងឺរលាកថ្លើមប្រភេទអា និងប្រភេទបេ តែវាអាចមានតម្លៃថ្លៃ ហើយមិនអាចរកបាននៅគ្រប់កន្លែងទេ។ ជំងឺរលាកថ្លើមប្រភេទបេ មានគ្រោះថ្នាក់ ហើយគ្មានការព្យាបាលឲ្យជាទេ ដូច្នេះបើមានថ្នាំបង្ការ ចូលទៅដល់កន្លែងរបស់អ្នក កុមារទាំងអស់គួរទទួលការចាក់ថ្នាំបង្ការនេះ។

***បំរាម ៖*** ជំងឺរលាកថ្លើមក៏អាចឆ្លងបានតាមរយៈការចាក់ថ្នាំដោយប្រើម្ជុលដែលមិនបានរំងាប់មេរោគ។ **ត្រូវតែស្ងោរម្ជុល និងស៊ីរ៉ាំងជានិច្ច មុនប្រើប្រាស់**(ទំ.៧៤)។

# ជំងឺរលាកសន្លាក់

ជំងឺរលាកសន្លាក់រ៉ាំរ៉ៃភាគច្រើនដែលកើតលើមនុស្សចាស់ មិនអាចព្យាបាលឲ្យជាជាស្ថាពរទេ។ ប៉ុន្តែ វិធីខាងក្រោម អាចជួយសម្រាលបានខ្លះ ៖

- **សម្រាក** បើអាចធ្វើបាន ជៀសវាងធ្វើការធ្ងន់ និងការហាត់ប្រាណធ្ងន់ ដែលរំខានដល់សន្លាក់ដែលកំពុងមានការឈឺចាប់នោះ។ បើជំងឺរលាកសន្លាក់បណ្តាលឲ្យមានគ្រុនក្តៅ នោះការសម្រាកពេលថ្ងៃអាចជួយបាន។
- **ដាក់ក្រណាត់ដែលជ្រលក់ទឹកក្តៅ ស្អំលើ**កន្លែងសន្លាក់ឆ្អឹងដែលឈឺ(អានទំ.១៩៥)។
- **អាស្ពីរីន** អាចជួយបន្ថយការឈឺចាប់។ កម្រិតប្រើថ្នាំនេះ សម្រាប់ជំងឺរលាកសន្លាក់ គឺខ្ពស់ជាងការប្រើសម្រាប់បំបាត់ការឈឺចាប់ផ្សេងទៀត។ មនុស្សធំត្រូវលេប ៣គ្រាប់ ៤ទៅ៦ដងក្នុងមួយថ្ងៃ។ បើត្រចៀករបស់អ្នកចាប់ផ្តើមហ៊ឹង ប្រើតិចជាងនេះ។ **ដើម្បីជៀសវាងការបញ្ហាក្រពះដែលបណ្តាលមកពីអាស្ពីរីន លេបវាជាមួយអាហារ ឬផឹកទឹកឲ្យច្រើន។** ប្រសិនបើការឈឺក្រពះនៅតែបន្ត លេបអាស្ពីរីនដោយមិនគ្រាន់តែជាមួយអាហារ និងទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រើជាមួយថ្នាំប្រឆាំងអាស៊ីត ដូចជា ម៉ាឡុក(Maalox) ឬ ថ្នាំហ្សេលុយស៊ីល(Gelusil) ចំនួនមួយស្លាបព្រាផងដែរ។
- **ការហាត់ប្រាណ**បន្តិចបន្តួចជាការសំខាន់ ក្នុងការរក្សាចលនារបស់សន្លាក់។



បើមានសន្លាក់តែមួយហើម ហើយក្តៅ នោះវាអាចមានការបង្ករោគហើយ ជាពិសេសប្រសិនបើមានគ្រុនក្តៅ។ ប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាថ្នាំប៉េនីស៊ីលីន (ទំ.៣៥១) ហើយបើអាចធ្វើបាន ទៅជួបភ្នាក់ងារសុខាភិបាល។

ការឈឺចាប់សន្លាក់ឆ្អឹងចំពោះមនុស្សជំទង់ និងកុមារ អាចជាសញ្ញានៃជំងឺធ្ងន់ធ្ងរផ្សេងទៀត ដូចជា ជំងឺរលាកសន្លាក់(ទំ.៣១០) ឬជំងឺរបេង (ទំ.១៧៩)។

# ការឈឺឆ្អឹងខ្នង

ការឈឺឆ្អឹងខ្នងមានមូលហេតុជាច្រើនយ៉ាង។ នេះគឺជាមូលហេតុមួយចំនួន ៖

*ការឈឺឆ្អឹងខ្នងផ្នែកខាងលើរ៉ាំរ៉ៃ ដោយមានក្អក និងស្រកទំងន់ អាចជាជំងឺរបេងសួត (ទំ.១៧៩)។*



*ការឈឺឆ្អឹងខ្នងផ្នែកកណ្តាល ចំពោះកុមារ អាចសន្និដ្ឋានថាជាជំងឺរបេងឆ្អឹងខ្នង។ ជាពិសេសបើឆ្អឹងខ្នង គម ឬមានពក។*

*ការឈឺឆ្អឹងខ្នងផ្នែកខាងក្រោម ដែលមានឈឺចាប់កាន់តែខ្លាំង បន្ទាប់ពីថ្ងៃដែលបានលើកឥវ៉ាន់ធ្ងន់ វាអាចបណ្តាល មកពីការថ្ងោះ។*

*ការឈឺឆ្អឹងខ្នងផ្នែកខាងក្រោមខ្លាំង ដែលទើបតែចាប់ផ្តើមភ្លាមៗនៅពេលលើកធ្ងន់ឬរមួល អាចបណ្តាលមកការភ្ញាត់កំណល់ឆ្អឹងខ្នង។*

*ជាពិសេសបើជើង ឬប្រអប់ជើងម្ខាងឈឺខ្លាំង ឬស្ពឹក ហើយខ្សោយ នេះអាចមកពីការគាបសរសៃប្រសាទ។*



*ការឈរ ឬអង្គុយខុសទំនង ដោយស្មារទាំងពីរធ្លាក់ គឺជាមូលហេតុញឹកញាប់នៃការឈឺឆ្អឹងខ្នង។*



*ចំពោះមនុស្សចាស់ ការឈឺឆ្អឹងខ្នងរ៉ាំរ៉ៃច្រើនតែជាជំងឺរលាកសន្លាក់ឆ្អឹង។*

*ការឈឺចាប់ឆ្អឹងខ្នងផ្នែកខាងលើ និងផ្នែកខាងស្តាំ អាចបណ្តាលមកពីបញ្ហាថង់ទឹកប្រមាត់(ទំ.៣២៩)។*

*ការឈឺចាប់ស្រួចស្រាល់ ឬរ៉ាំរ៉ៃនៅត្រង់នេះអាចបណ្តាលមកពីបញ្ហាផ្លូវទឹកនោម (ទំ.២៣២)*

*ការឈឺឆ្អឹងខ្នងផ្នែកខាងក្រោម ជាការធម្មតាចំពោះមនុស្សស្រីខ្លះ នៅពេលមាន រដូវនិងពេលមានផ្ទៃពោះ (ទំ.២៤៨)។*

*ការឈឺចាប់ឆ្អឹងខ្នងផ្នែកខាងក្រោម ជួនកាលអាចបណ្តាលមកពីបញ្ហាក្នុងស្បូន អូវ៉ែ ឬចុងពោះវៀនធំ។*

*ការព្យាបាល និងការបង្ការការឈឺឆ្អឹងខ្នង ៖*

- បើការឈឺឆ្អឹងខ្នងមានមូលហេតុដូចជា មានជំងឺរបេង ជំងឺផ្លូវទឹកនោម ឬជំងឺចង់ទឹកប្រមាត់ ព្យាបាលមូលហេតុទាំងនេះ។ ស្វែងរកជំនួយពីគ្រូពេទ្យ ប្រសិនបើអ្នកសង្ស័យថាជាជំងឺធ្ងន់ធ្ងរ។
- ការឈឺឆ្អឹងខ្នងធម្មតា ព្រមទាំងឈឺពេលមានផ្ទៃពោះ ជារឿយៗគេអាចការពារបានឬធ្វើឲ្យធូរស្រាលដោយ ៖

*ឈរឲ្យត្រង់ខ្លួន ដូចរូបនេះ*




*ដេកលើគ្រែឬពូករឹងដូចនេះ*




*ហាត់ប្រាណ ដោយឱនងើបទាបៗយឺតៗ*



- ការលេបអាស្ពីរីន (Aspirin) និងស្អំទឹកក្តៅ (ទំ.១៩៥) ជួយសម្រាលការឈឺចាប់ខ្នងសឹងតែគ្រប់ផ្នែក។
- ចំពោះការឈឺចាប់ឆ្អឹងខ្នងផ្នែកខាងក្រោមដែលបណ្តាលមកពីការរមួល ការលើកដាក់របស់ធ្ងន់ ការឱន ឬការចុករោយ គេអាចបន្ថយការឈឺចាប់យ៉ាងរហ័សដោយ ៖

*ដាក់ឲ្យដេកដោយព័ន្ធជើងម្ខាងក្រោមជង្គង់*



*បន្ទាប់មកសង្កត់ស្មារចុះ ថ្នមៗ ហើយរុញជង្គង់ឲ្យជាប់ ដើម្បីបង្វិល។ ដំបូងធ្វើម្ខាង រួចធ្វើម្ខាងទៀត។*

*ប្រុងប្រយត្ន័ ៖* កុំព្យាយាមធ្វើដូច្នេះបើសិនការឈឺឆ្អឹងខ្នងបណ្តាលមកពីដួលឬមានរបួស។

- បើការឈឺចាប់ឆ្អឹងខ្នងកើតឡើងភ្លាមៗដោយសារការលើករបស់ ឬការរមួល ហើយឈឺខ្លាំង ដូចជាកាំបិតចាក់នៅពេលដែលអោន ហើយប្រសិនបើការឈឺចាប់រាលដល់ជើង ឬបើប្រអប់ជើងទៅជាស្ពឹក ឬខ្សោយ នោះជាសភាពធ្ងន់ធ្ងរ។ សរសៃប្រសាទដែលមកពីឆ្អឹងខ្នងអាចគាបដោយកំណល់ចន្លោះឆ្អឹងកងខ្នង។ ការដេកសម្រាករយៈពេលពីរបីថ្ងៃគឺជាការល្អប្រសើរ។ វាអាចជួយផងដែរ បើគេដាក់របស់អ្វីមួយឲ្យមាំកល់ក្រោមជង្គង់ និងចំកណ្តាលខ្នង។



- លេបអាស្ពីរីននិងស្អំដោយក្រណាត់ជ្រលក់ទឹកក្តៅ។ បើការឈឺចាប់នៅតែមិនធូរស្រាលក្នុងអំឡុងពីរបីថ្ងៃ ទៅរកការពិគ្រោះយោបល់ពីគ្រូពេទ្យ។

# ជំងឺប៉ោងសរសៃវ៉ែន

ជំងឺប៉ោងសរសៃវ៉ែន គឺសំដៅលើសរសៃវ៉ែនដែលហើម រមួល និងឈឺចាប់ជាញឹកញាប់។ គេច្រើនជួបប្រទះលើជើងមនុស្សចាស់ និងស្ត្រីមានគភ៌ ឬអ្នកដែលមានកូនច្រើន។

*ការព្យាបាល ៖*



ពុំមានថ្នាំសម្រាប់ព្យាបាលជំងឺប៉ោងសរសៃវ៉ែនទេ ប៉ុន្តែការអនុវត្តន៍ដូចខាងក្រោមនេះអាចជួយបាន ៖

- កុំឈរ ឬអង្គុយសំយុងជើងយូរ ប៉ុន្តែបើគ្មានជំរើស ដោយត្រូវអង្គុយ ឬឈរយូរ ព្យាយាមទំរេតហើយលើកជើងឡើងបន្តិច (ឲ្យខ្ពស់ជាងបេះដូង) រយៈពេលពីរបីនាទី នៅរៀងរាល់កន្លះម៉ោងម្តង។ នៅពេលឈរ ព្យាយាមធ្វើចលនាដើរនៅមួយកន្លែង។ ឬលើកកែងជើងឲ្យផុតពីដី ហើយដាក់ចុះវិញ។ ម្យ៉ាងទៀត ត្រូវដេកដាក់ជើងឡើងលើផងដែរ(កល់ខ្នើយ)។
- ប្រើស្រោមជើងយឺត ឬក្រណាត់រុំយឺតៗ ដើម្បីជួយទប់សរសៃវ៉ែន។ ត្រូវសាយ្រវាចេញនៅពេលយប់។
- ការថែរក្សាសរសៃវ៉ែនរបស់អ្នកតាមរបៀបនេះ នឹងជួយការពារមិនឲ្យមានការឈឺចាប់រ៉ាំរ៉ៃ ឬមិនឲ្យមាន **ដំបៅនៅភ្នែកជើង** ដែលបណ្តាលមកពីការរីកសរសៃវ៉ែននេះ(ទំ.២១៣)។

# ឫសដូងបាត

ឫសដូងបាតគឺជាការរីកប៉ោងសរសៃវ៉ែននៅគូថ ឬរន្ធគូថ ដែលមានរាងដូចជាដុំសាច់ឬគ្រាប់តូចៗ។ វាអាចមានការឈឺចាប់ខ្លាំង ប៉ុន្តែមិនមានគ្រោះថ្នាក់ទេ។ បញ្ហានេះច្រើនកើតនៅពេលមានគភ៌ ហើយបាត់ទៅវិញបន្ទាប់ពីសម្រាលកូនរួច។




- ទឹករុក្ខជាតិខ្លះដែលមានជាតិល្វីងអាចយកទៅស្អំលើឫសដូងបាត អាចជួយឲ្យវារួមតូចវិញបាន។ គេក៏អាចព្យាបាលឫសដូងបាតដោយប្រើថ្នាំសុលតាមរន្ធគូថផងដែរ (ទំ.៣៩២)។
- ការអង្គុយត្រាំនៅក្នុងទឹកក្តៅឧណ្ណៗអាចជួយព្យាបាលឫសដូងបាតដែរ។
- ជំងឺឫសដូងបាតក៏អាចបណ្តាលមកពីការទល់លាមកដែរ។ ការតបរិភោគផ្លែឈើ ឬអាហារដែលមានជាតិសរសៃឲ្យបានច្រើន ដូចជាដំឡូងឈើ ក៏អាចជួយដែរ។
- ឫសដូងបាតដែលធំខ្លាំង អាចតម្រូវការការវះកាត់។ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ។

ប្រសិនបើឫសដូងបាតចាប់ផ្តើមធ្លាក់ឈាម នោះដួនកាលការធ្លាក់ឈាមអាចគ្រប់គ្រងបានដោយការយកក្រណាត់ស្អាតមកសង្កត់ចំពីលើឫសដូងបាតនោះផ្ទាល់។ ប្រសិនបើឈាមនៅតែមិនឈប់ហូរ ស្វែងរកជំនួយពីគ្រូពេទ្យ។ ឬព្យាយាមឃាត់ឈាម ដោយការយកដុំឈាមកកនៅខាងក្នុងសរសៃឈាមប៉ោងនោះចេញ។ ដង្កៀបដូចនេះក៏អាចប្រើបានដែរ បន្ទាប់ពីបានរំងាប់មេរោគដោយការស្ងោររួច។

*ការប្រុងប្រយត្ន័ ៖* **មិនត្រូវព្យាយាមកាត់ឫសដូងបាតចេញឡើយ។** អ្នកជំងឺអាចហូរឈាមរហូតដល់ស្លាប់។

# ការហើមជើង និងផ្នែកផ្សេងទៀតនៃដងខ្លួន

ការហើមជើងអាចបណ្តាលមកពីបញ្ហាមួយចំនួនផ្សេងៗគ្នា ខ្លះមិនសូវមានគ្រោះថ្នាក់ ហើយខ្លះទៀតមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។ ប៉ុន្តែបើមុខ ឬផ្នែកដទៃទៀតនៃខ្លួនក៏ហើម នោះភាគច្រើនគឺជារោគសញ្ញានៃជំងឺធ្ងន់ធ្ងរហើយ។

ជួនកាលជើងស្ត្រីឡើងហើមក្នុងរយៈពេលបីខែចុងក្រោយនៃការមានផ្ទៃពោះ។ ជាទូទៅវាមិនមែនជាបញ្ហាធ្ងន់ធ្ងរទេ។ នេះ បណ្តាលមកពីទម្ងន់របស់ទារកដែលសង្កត់លើសរសៃឈាមវ៉ែននៃជើង ដែលបង្អាក់ចរន្តរត់របស់ឈាម។ បើដៃ និងមុខស្ត្រីមានហើម ហើយគាត់មានវិលមុខ ស្រវាំងភ្នែក ឬនោមតិច នោះគាត់អាចមានបញ្ហាព្រាយក្រឡាភ្លើង (ទំ.២៤៩)។ ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

មនុស្សចាស់ដែលអង្គុយយូរ ឬឈរយូរមួយកន្លែង ច្រើនហើមជើង ព្រោះដំណើរឈាមរត់មិនល្អ។ ប៉ុន្តែ ការហើមជើងចំពោះមនុស្សចាស់អាចបណ្តាលមកពីជំងឺបេះដូង (ទំ.៣២៥)ឬជំងឺតម្រងនោម (ទំ.២៣៤)តែជាបញ្ហាកំរ។

ការហើមជើងចំពោះកុមារ អាចបណ្តាលមកពីការមានភាពស្លេកស្លាំង (ទំ.១២៤) ឬកង្វះអាហាររូបត្ថម្ភ (ទំ.១០៧)។ ក្នុងករណីធ្ងន់ធ្ងរ មុខនិងដៃអាចឡើងហើមដែរ(មើលជំងឺខ្វាស្ប៉ូគ័រ ទំ.១១៣)។

*ការព្យាបាល ៖*

ដើម្បីបន្ថយការហើម ព្យាបាលជំងឺដែលបណ្តាលឲ្យហើមនេះ។ ប្រើអំបិលតិចតួច ឬកុំប្រើអំបិលនៅក្នុងអាហារ។ ទឹកតែរុក្ខជាតិដែលធ្វើឲ្យយើងនោមច្រើន (មើលសរសៃសក់ពោត ទំ.១២)ក៏អាចជួយដែរ។ ម្យ៉ាងទៀត ធ្វើដូចខាងក្រោម ៖

*នៅពេលដែលជើងរបស់អ្នកឡើងហើម ៖ កុំសំយុងជើងចុះក្រោមដូចនេះ។ វាបណ្តាលឲ្យជើងកាន់តែហើមខ្លាំងឡើង។*

ទេ



*នៅពេលអ្នកអង្គុយ លើកជើងឲ្យខ្ពស់។ ការធ្វើបៀបនេះ ការហើមនឹងធូរស្រាល។ លើកជើងអ្នកឲ្យខ្ពស់ឲ្យបានច្រើនដងក្នុងមួយថ្ងៃ។ គួរលើកជើងរបស់អ្នកឲ្យខ្ពស់ជាងបេះដូង។*

ល្អ



*ម្យ៉ាងទៀត ដេកដោយលើកជើងរបៀបនេះ។*

កាន់តែល្អ



# ជំងឺក្លូនលូន

ជំងឺក្លូនលូនគឺជាការបើកចំហរ ឬការហែកសាច់ដុំដែលគ្របពោះ បណ្តាលឲ្យផ្នែកមួយនៃពោះវៀនលូនចេញ ហើយបង្កើតបានជាដុំមួយនៅក្រោមស្បែក។ ជាទូទៅ ក្លូនលូនបណ្តាលមកពីការលើករបស់ធ្ងន់ ឬការប្រឹងខ្លាំង (ដូចជា ពេលសម្រាលកូន)។ ទារកខ្លះកើតមកដោយក្លូនលូនពិកំណើត (មើលទំ.៣១៧)។ ចំពោះមនុស្សប្រុស ក្លូនច្រើនកើតមាននៅត្រង់ក្រលៀន។ ការឡើងហើមកូនកណ្តុរ (ទំ.៨៨)ក៏អាចបណ្តាលឲ្យមានដុំពកត្រង់ក្រលៀនដែរ។ ទោះជាយ៉ាងណាក៏ដោយ...........




*វិធីបង្ការជំងឺក្លូនលូន*




*អ្នកកើតក្លូនត្រូវធ្វើយ៉ាងណា ៖*

- ចៀសវាងលើករបស់ធ្ងន់។
- ប្រើខ្សែក្រវាត់ទ្រកន្លែងដែលមានក្លូន។

*គម្រោងសម្រាប់ធ្វើខ្សែក្រវាត់យ៉ាងងាយ ៖*




*ប្រយត្ន័ ៖* បើក្លូនលូនប៉ោងធំ ឬមានការឈឺចាប់ភ្លាមៗ ត្រូវសាកល្បងរុញវាបញ្ចូលទៅវិញ ដោយឲ្យអ្នកជំងឺដេកលើកជើងឲ្យខ្ពស់ជាងក្បាល ហើយសង្កត់ថ្នមៗទៅលើកន្លែងដែលប៉ោងនោះ។ បើរុញវាមិនចូលវិញទេ ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

**បើក្លូនមានការឈឺចាប់យ៉ាងខ្លាំង និងបណ្តាលឲ្យមានក្អួត និងអ្នកជំងឺគ្មានបត់ជើងធំទេ នោះអាចជាបញ្ហាគ្រោះថ្នាក់ណាស់។** គេអាចត្រូវការការវះកាត់ជាចាំបាច់។ ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។ ក្នុងពេលជាមួយគ្នានេះធ្វើការព្យាបាលដូចជំងឺរលាកខ្នែងពោះវៀនដែរ (ទំ.៩៥)។

# ការប្រកាច់

យើងនិយាយថាមនុស្សម្នាក់មានការប្រកាច់ នៅពេលដែលអ្នកនោះបាត់បង់ស្មារតីភ្លាមៗ ហើយមានសកម្មភាពចម្លែកៗ និងចលនាញាក់ញ័រ។ ការប្រកាច់បណ្តាលមកពីការមានបញ្ហានៅក្នុងខួរក្បាល។ ជាទូទៅការប្រកាច់ចំពោះកុមារតូចៗ បណ្តាលមកពីមាន**គ្រុនក្តៅខ្លាំង** និង**ការខ្សោះជាតិទឹកធ្ងន់ធ្ងរ**។ ចំពោះអ្នកជំងឺធ្ងន់ធ្ងរ មូលហេតុអាចបណ្តាលមកពីជំងឺ**រលាកស្រោមខួរក្បាល គ្រុនចាញ់ដែលប៉ះពាល់ដល់ខួរក្បាល** ឬ**ការពុលអ្វីផ្សេងៗ**។ អ្នកដែលមានការប្រកាច់ញឹកញាប់ អាចមាន**ជំងឺឆ្កួតជ្រូក**។

- ព្យាយាមរកមូលហេតុនៃការប្រកាច់ ហើយព្យាបាលវាបើអាចធ្វើបាន។
- បើកុមារមានគ្រុនក្តៅខ្លាំង ត្រូវបញ្ចុះកម្តៅដោយប្រើទឹកត្រជាក់ភ្លាមៗ (ទំ.៧៦)។
- បើកុមារមានការខ្សោះជាតិទឹក ឲ្យផឹកទឹកអូ៉រ៉ាលីត**បន្តិចម្តងៗ**។ រកជំនួយពីគ្រូពេទ្យ។ មិនត្រូវឲ្យអ្វីតាមមាត់ពេលដែលគេកំពុងប្រកាច់នោះឡើយ។
- បើមានរោគសញ្ញាជំងឺរលាកស្រោមខួរក្បាល (ទំ.១៨៥) ត្រូវចាប់ផ្តើមព្យាបាលភ្លាមៗ ហើយស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។
- បើអ្នកសង្ស័យថាមានជំងឺគ្រុនចាញ់ដែលប៉ះពាល់ដល់ខួរក្បាល ព្យាបាលជំងឺគ្រុនចាញ់ (ទំ.៣៦៧)។

# ជំងឺឆ្កួតជ្រូក

ជំងឺឆ្កួតជ្រូកជាជំងឺដែលបណ្តាលឲ្យមានការប្រកាច់ មិនថាចំពោះអ្នកដែលមានសុខភាពល្អក៏ដោយ។ ការប្រកាច់អាចកើតឡើងចន្លោះពីគ្នាជាច្រើនម៉ោង ច្រើនថ្ងៃ ច្រើនអាទិត្យ ឬច្រើនខែ។ ចំពោះអ្នកខ្លះ វាអាចធ្វើឲ្យមានការបាត់បង់ស្មារតី និងមានចលនាយ៉ាងខ្លាំង។ ភ្នែកអ្នកជំងឺប្រភេទនេះច្រើនវិលក្រឡាប់ទៅក្រោយ។ ចំពោះជំងឺឆ្កួតជ្រូកកម្រិតស្រាល អ្នកជំងឺអាចមានការភាំងស្មារតីភ្លាមមួយរយៈ មានសកម្មភាពចម្លែកៗ ឬធ្វើអ្វីប្លែកៗ។ ជំងឺឆ្កួតជ្រូកច្រើនកើតមានតាមគ្រួសារខ្លះ(ជំងឺតំណពូជ) ឬវាអាចបណ្តាលមកពីមានការប៉ះពាល់ខួរក្បាលពីកំណើត មានគ្រុនក្តៅខ្លាំងក្នុងវ័យទារក ឬមានពងព្រូនសំប៉ែតនៅក្នុងខួរក្បាល(ទំ.១៤៣)។ ជំងឺឆ្កួតជ្រូកមិនមែនជាជំងឺដែលបណ្តាលមកពីមេរោគទេ ហើយវាក៏កម្រកើតដែរ។ ជាទូទៅ វាជាជំងឺរ៉ុំារ៉ៃក្នុងមួយជីវិត ប៉ុន្តែកុមារខ្លះជួនកាលអាចជាវិញដែរ។

*ថ្នាំសម្រាប់បង្ការការប្រកាច់ដោយជំងឺឆ្កួតជ្រូក ៖*

**កំណត់សំគាល់ ៖** ថ្នាំទាំងនេះ មិនអាចព្យាបាលជំងឺឆ្កួតជ្រូកឲ្យជាជាស្ថាពរទេ វាគ្រាន់តែជួយបង្ការការប្រកាច់ប៉ុណ្ណោះ។ ជាទូទៅ គេត្រូវប្រើថ្នាំអស់មួយជីវិត។

- ជាទូទៅ ថ្នាំហ្វេណូបាប៊ីតាល់(Phenobarbital) អាចជួយក្នុងជំងឺឆ្កួតជ្រូកបាន ហើយវាមានតម្លៃថោកផង (ទំ.៣៨៩)។
- ថ្នាំហ្វេនីតូអ៊ីន(Phenytoin) អាចមានប្រសិទ្ធភាព បើហ្វេណូបាប៊ីតាល់(Phenobarbital)គ្មានប្រសិទ្ធភាព។ ប្រើកម្រិតទាបបំផុតតាមដែលអាចធ្វើបាន ដើម្បីបង្ការការប្រកាច់(ទំ.៣៩០)។

**នៅពេលមនុស្សម្នាក់កំពុងប្រកាច់ ៖**



- ព្យាយាមការពារអ្នកជំងឺពីការបង្ករបួសផ្សេងៗដល់ខ្លួនគាត់។ យកសម្ភារៈ វត្ថុរឹង ឬមុតស្រួចចេញឲ្យឆ្ងាយ។
- មិនត្រូវដាក់អ្វីក្នុងមាត់អ្នកជំងឺពេលដែលគាត់កំពុងប្រកាច់ ដូចជាមិនត្រូវផ្តល់អាហារ ភេសជ្ជៈ ថ្នាំពេទ្យ ឬវត្ថុអ្វីផ្សេងទៀតដើម្បីបង្ការការខាំអណ្តាត។
- បន្ទាប់ពីប្រកាច់ អ្នកជំងឺអាចសំងំ និងងងុយដេក។ ឲ្យគាត់ដេក។
- ប្រសិនបើការប្រកាច់មានរយៈពេលលើសពី១៥នាទី ត្រូវចាក់បញ្ចូលទឹកថ្នាំឌីយ៉ាហ្សេប៉ាម(Diazepam)តាមរន្ធគូថដោយប្រើស៊ីរ៉ាំងប្លាស្ទិក **ដោយមិនប្រើម្ជុល**។ សម្រាប់កម្រិតនៃការប្រើប្រាស់ មើលទំព័រ ៣៩០។ មិនត្រូវចាក់ហ្វេណូបាប៊ីតាល់ (Phenobarbital) ឬហ្វេនីតូអ៊ីន(Phenytoin) ឬឌីយ៉ាហ្សេប៉ាម(Diazepam) តាមសាច់ដុំឡើយ។ ការចាក់ថ្នាំទាំងនេះ អាចបណ្តាលឲ្យមានគ្រោះថ្នាក់ណាស់ ប្រសិនបើអ្នកគ្មានបទពិសោធន៍គ្រប់គ្រាន់។ មានតែអ្នកដែលមានបទពិសោធន៍ខាងចាក់ថ្នាំតាមសរសៃប៉ុណ្ណោះដែលអាចចាក់ថ្នាំទាំងនេះបាន។